- មិនបាច់ទេ ! ( ជិនពោលដាច់អហង្ការ ) គិតតែខ្លួនឯងទៅ ប្រញាប់ឡើង នពេលវេលា រឿងបងប្អូនទុកដោយខ្មែរ ! ខ្ញុំជាប្រធានកងនៅទីនេះទទួលខុសត្រូវហើយ ... ទៅ ! ទៅៗនាំគ្នាយកបាឡ សម្លៀកបំពាក់ទៅ ! នារីសារេគេនៅចាំ ។

- ចាស ...

* *

*



# ៨

## លេចផ្ទើលេបក្រើស

ភាសា "សន្តិសុខ" របស់អង្គការខ្មែរក្រហម រាប់ករណីមិនជាស្ថាប័នសន្តិភាពសំរាប់ត្រួតត្រាសណ្តាប់ធ្នាប់សង្គមឱ្យល្អនោះទេ តាមពិតកន្លែងឃុំឃាំងមនុស្ស ឬ គុកសំរាប់ដាក់ប្រជាជន ដែលត្រូវគេចោទថាអ្នកបានធ្វើការប្រឆាំងមាគ៌ាបដិវត្តគេនោះ ។ មនុស្សរាល់រូបគ្រាន់ពាក្យ "សន្តិសុខ" នេះឡើងព្រឺ ស្រៀវដល់ឆ្អឹងខ្នងព្រោះសមត្ថកិច្ចនគរបាល ខាងច្បាប់និងគោលការស្ថិតនៅក្នុងសន្តិសុខទាំងអស់ ។

នាងសម្ផស្សឥតបានដឹងខ្លួនថា គេនាំនាងទៅកាន់បន្ទាយសន្តិសុខនោះទេ លុះត្រាប់តែទៅដល់ទីនោះ ទើបនាងភ្ញាក់ខ្លួនព្រឺតរន្ធត់ម្ដង ។ សារៈយកនាងទៅដាក់នៅក្នុងបន្ទប់ផ្ទះតៀមមួយ រួចគេដើរចេញទៅឥតមាននិយាយប្រាប់ថាមេចឡើយ ។ នាងចេះតែគិតថា ហេតុអ្វីជាគេនាំនាងមកកាន់ទីនេះ ? នាងមានពាក់ព័ន្ធរឿងអ្វីដែលត្រូវគេយកមកអប់រំលត់ដំ ឬ ដាក់គុក ? ទេ ! ចាប់តាំងពីដើមមកនាងតាំងចិត្តប្រព្រឹត្តតែអំពើល្អ ហើយក្នុងរដ្ឋអំណាចខ្មែរក្រហមគ្រប់គ្រង

នេះ នាងមិនដែលធ្វើសកម្មភាព ឬ ចលនារឹងស្អះចំពោះអធិបតីគេ ឡើយ ។

ប្រហែលម៉ោងប្រាំល្ងាច ទើបមាននារីសន្តិសុខម្នាក់ មកនាំ សម្ពស្សចេញទៅជួបនឹងប្រធានមន្ទីររបស់គេ ។ សម្ពស្សភ្ញាក់ខ្លួនព្រើត ម្ដងទៀត កាលឃើញមុខប្រធានអង្គភាពនេះ គឺជាបុរសដែលបានសុំមួក ស្លឹកត្នោតរបស់នាង ។ បុរសនេះហើយឈ្មោះម៉ាន់ ។ ម៉ាន់ ជាប្រធានមន្ទីរសន្តិសុខស្រុកមេសាង ។

ម៉ាន់អង្គុយលើកៅអីក្រោយតុសរសេរដ៏តូចមួយ បញ្ចេញទឹកមុខ ញញឹមសំដែងការរាក់ទាក់មកកាន់នាងសម្ពស្ស :

– សម្ពស្សចូលម៉ោ ! . . កុំញញើតញញើមអី អង្គុយលើគ្រែខាង ណេះទៅ !

ភាពញញឹមនិងសម្ដីស្រទន់របស់បុរសម៉ាន់ ធ្វើឲ្យមាណវីអធំបុក ពោះបន្តិច ។

– សម្ពស្ស នៅចាំមុខខ្ញុំបានទេ ? (ម៉ាន់និយាយឡើងម្ដងទៀត)។

សម្ពស្សចូលទៅអង្គុយស្រប់ កាលឮគេសួរដូច្នេះ ក៏ងើបមុខឡើង ឆ្លើយតប ៖

– ចាស ខ្ញុំនៅចំណាំមុខលោកពូបាន . . .

– ហាក ! កាលមុនហៅខ្ញុំ ថាមិត្តបង ឥឡូវម៉េចក៏ហៅពូទៅវិញ?



– ចាស ខ្ញុំខ្លួចជាភ្លេចមិនបាននឹកឃើញថា កាលណោះហៅ លោកពូថាមិត្តបងទេ . . . ប៉ុន្តែបើជាការសមរម្យគួរខ្ញុំ ហៅថា លោក ពូវិញព្រោះលោកពូមានវ័យចំណាស់ ប្រៀបបានឪពុករបស់ខ្ញុំទៅហើយ។

ម៉ាន់ចាប់សើចកក្អឹកបង្ហាញចិត្តថ្មើម ឲ្យនាងឃើញថាគេមិនមែន ជាមនុស្សប្រកែកប្រកាន់ :

– មិនអីទេ ខ្ញុំមិនចេះប្រកាន់ទោសអស់ដំណើរទេណា៎ ហៅខ្ញុំពូ អញ្ចឹងក៏បានដែរ . . . សម្ពស្ស ខ្ញុំពេញចិត្តនឹងឥរិយាបថសុភាពរាប សាររបស់មិត្តណាស់ ! ខ្ញុំបានឃើញមិត្តនៅក្នុងកងចល័ត ធ្វើការហត់ នឿយរហូតដល់ឈឺថ្កាត់ រស់នៅក្នុងភាពដុនដាប ខ្ញុំនឹកអាណិតមិត្ត ណាស់បានជាខ្ញុំសំរេចចិត្តយកមិត្តនារីមកនៅអង្គភាពជាមួយខ្ញុំនេះ ។

សម្ពស្សនៅចាំស្គាល់កម្ពុជ្ជនៃការកោះហៅរូបនាងយូរហើយ ទើប ពេលនេះបានដឹងច្បាស់ នាងក៏ទាញក្រមាជូតញើសពេញថ្ងាស ។ នាងគ្រាន់តែទប់បានការភិតភ័យបំណោះ ប៉ុន្តែចិត្តនាងគ្មានគោល បំណងចង់ចូលធ្វើការក្នុងរបបនេះបន្តិចទេ ព្រោះនាងនឹកឃើញថា កាល មុនឪពុករបស់នាង និងរូបនាងបានចូលរួមចំណែកក្នុងចលនាតស៊ូរំដោះ ជាតិដែរ តែដល់ទីបំផុតគេក្បាយរបបខុសពីបំណងចង់បានរបស់ប្រជា– ជន ។

– ម៉េចសម្ពស្ស ? ( ម៉ាន់សួរបញ្ជាក់ ) ខ្ញុំយកមិត្តមកធ្វើការ នៅក្នុងអង្គភាពសន្តិសុខរបស់ខ្ញុំ ពេញចិត្តទេ ?

–

– ចាស ! ទោះពេញចិត្តឬមិនពេញចិត្ត បើពូបញ្ជាយកខ្ញុំមកនៅទីនេះហើយខ្ញុំពុំអាចប្រកែកបានទេ ខ្ញុំគោរពតាមអត្តការ ...

– អើ និយាយឲ្យត្រង់ៗអញចូលចិត្តស្រួលស្តាប់ ... សម្ផស្ស ខ្ញុំយល់ថាមិត្តនារីប៉ិនប្រសប់ដេរមក អញ្ចឹងទេ មុនដំបូងនេះខ្ញុំប្រគល់ភារកិច្ចឲ្យមិត្ត ធ្វើមួកស្លឹកត្នោត សំរាប់ផ្តល់ឲ្យមិត្តយើងពាក់ធ្វើការ ។

– ចាស តាមតែពូមេត្តាស្រេចទៅចុះ ពូចាត់តាំងឲ្យខ្ញុំធ្វើការអី ខ្ញុំនឹងខិតខំបំពេញអស់ពីកម្លាំងកាយ ។

– អឺ ... ការងារសង្គមនិយមមានច្រើន ... តែឥឡូវចុះមិត្តធ្វើការលុមៗ បានហើយ ក្រោយពីនេះមក មិត្តមកជួយបោសសំអាតកន្លែងធ្វើការរបស់ខ្ញុំផង ។

– ចាស ...

បញ្ចប់ការពិភាក្សា ម៉ាន់ប្រាប់សម្ផស្សឲ្យចេញមកអង្គុយលេងនៅគ្រែខាងក្រៅ ។ គេហៅនារីសន្តិសុខម្នាក់ ដែលជាអ្នកប្រចាំការបំរើនៅទីនោះទៅនិយាយតិចៗ រួចនារីនោះក៏ដើរចេញទៅបាត់ ។ បន្តិចក្រោយមកក៏លេចនារីម្នាក់ទៀត ស្ថិតនៅក្នុងវ័យកណ្តាល ចូលមកជួបម៉ាន ។ ម៉ាន់និយាយប្រាប់នារីនេះ ពីការដែលខ្លួនយកនាងសម្ផស្សចូលធ្វើការ ។ គេឮសំដីនារីវ័យកណ្តាលនេះ និយាយឆ្លងឆ្លើយនឹងម៉ាន់ប្រែត ។ ហាក់ដូចជាគេមានសិទ្ធិស្មើនឹងម៉ាន់ដែរ ។ ម៉ាន់សរុបសេចក្តីដោយពោលបញ្ចប់ចុងក្រោយថា :



– មិត្តយ៉ិត ! មិត្តជាប្រធានក្រុមនារីស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំ មិត្តត្រូវឯកភាពតាមខ្ញុំផង ឥឡូវនេះខ្ញុំប្រគល់នារីសម្ផស្សឲ្យមិត្តជួយមើលការខុសត្រូវ ហើយចាត់ចែងភារកិច្ចទៅតាមបំណងរបស់ខ្ញុំដែលបានលើកឡើងប្រាប់មិត្ត ... ទៅចុះរកកន្លែងឲ្យសម្ផស្សស្នាក់នៅសមរម្យផង ។

យ៉ិតដើរចេញមកទាំងទឹកមុខស្មើ ឃើញសម្ផស្សអង្គុយលើគ្រែនៅមុខបន្ទប់នោះក៏បោះសម្តី :

– ម៉ោ ! ម៉ោតាមខ្ញុំ

គេនាំនាងសម្ផស្សទៅកាន់ផ្ទះស្នាក់អាស្រ័យខាងក្រុមនារី ហើយប្រគល់បន្ទប់តូចមួយឲ្យនាងដេកនៅតែម្នាក់ឯង ។ ចាប់ពីពេលនោះមកនាងសម្ផស្សបានប្រែជីវភាពពីយុវនារីកងចល័ត ទៅជាបុគ្គលិកបំរើម្នាក់នៃមន្ទីរសន្តិសុខស្រុក ។

រាល់ថ្ងៃសម្ផស្សតែងបានសង្កេតមើលទៅលើកន្លែងមួយ ដែលនៅឃ្លាតពីមន្ទីរសន្តិសុខប្រហែលមួយរយម៉ែត្រ ។ ទីនោះមានផ្ទះវៀងមួយបិទបាំងដោយជញ្ជាំងយ៉ាងមាំទាំនិង មានរោងប្រសាលពីរទៀតប្រក់ស្លឹករយីករយាក ។ នាងបានឃើញមនុស្សជាច្រើនធ្វើការរញឹករញាក់ថ្ងៃត្រៃគ្មានឈប់សំរាក ។ មនុស្សទាំងនោះគឺសុទ្ធតែជាអ្នកទោសដែលត្រូវគេចាប់យកមកដាក់ឃុំឃាំង រាល់ខែ រាល់ឆ្នាំមកហើយ ។ តាមពួកនារីសន្តិសុខដែលទទួលខុសត្រូវខាងផ្តល់ស្បៀងអាហារដល់អ្នក

ទោសទាំងនោះហើយដែលស្គាល់ចិត្តថ្លើមនាង សម្ផស្សបានលួចនិយាយប្រាប់ការពិតថា មានអ្នកទោសធ្ងន់ៗច្រើននាក់ត្រូវដាក់ខ្នោះដៃ ខ្នោះជើង ជាប់នៅក្នុងគុកនោះ គ្មានដែលឃើញពន្លឺថ្ងៃទេ ជនណាមានទោសមធ្យម ពេលថ្ងៃគេបញ្ចេញឲ្យធ្វើការ ពេលយប់បញ្ចូលទៅក្នុងគុកវិញ ដាក់ខ្នោះ ឬ ដាក់ច្រវាក់ ។ ជនដែលជាប់ឃុំឃាំងយូរឆ្នាំមកហើយ ត្រូវបានគេសម្រាលទោស គេបើកលែងឲ្យធ្វើការនិងស្នាក់អាស្រ័យនៅខាងក្រៅ ។ មានជនមួយប្រភេទទៀតគាត់ទុក ដូចជាអស់ទោសហើយ ប៉ុន្តែគេមិនបានដោះលែងឲ្យវិលទៅលំនៅឋានជួបជុំគ្រួសារវិញទេ គេទុកអ្នកទាំងនោះឲ្យនៅធ្វើការបម្រើអង្គភាពសន្តិសុខនេះតែម្តង។ ការងារទាំងនោះគឺការធ្វើពលកម្ម បង្កបង្កើនផលដំណាំ និង ធ្វើស្រែ ដូចនៅសហករណ៍ដែរ ។ ប៉ុន្តែការលំនៅមានសភាពធូរធារហើយ របបហូបចុកកំរិតជាអប្បបរិមា ។ ម្ល៉ោះហើយការឈឺថ្កាត់មានជាបន្តបន្ទាប់ ការស្លាប់បាត់បង់ជីវិតមានជាហូរហែ . . . ស្លាប់ដោយជម្ងឺបាក់កម្លាំងស្គមស្គាំងរីងរៃ និង ស្លាប់ដោយគេយកទៅសម្លាប់ពីបទចោទប្រកាន់ថាកាសេបេ ចលនាក្បាលស្ពាន់បដិវត្តន៍ . . .

យប់មួយខែភ្លឺចែស សម្ផស្សចេញមកក្រៅផ្ទះ ស្រាប់តែក្រឡេកទៅឃើញទាហានសន្តិសុខមួយក្រុម បញ្ចេញអ្នកទោសពីគុក ពីរ បីនាក់ ហើយបណ្តើរចេញទៅ . . . ដោយមានសំឡេងដង្ហោយយំផងអង្វរករផង មិនដឹងជាគេយកទៅណា . . . ទៅធ្វើអីទេ ។ នាង



ឃើញទិដ្ឋភាពបែបនេះក៏ស្រៀវខ្លួន និង ព្រឺក្បាលសំពោង ប្រញាប់រត់ចូលបន្ទប់សំរាកវិញ ។ នាងគូសវាសក្នុងអារម្មណ៍ នឹកឃើញថាអ្នកដែលត្រូវគេប្រមូលប្រទាញទៅនោះ គ្មានពេលបានទៅឃើញលោកនេះទេ ! ។ នាងពិចារណាយល់ខ្លួននាងផ្ទាល់ពិតមែនហើយថា នាងមាននាមជាបុគ្គលិកបំរើការងារនៅមន្ទីរសន្តិសុខនេះ ប៉ុន្តែបើសិនជាមានការខុសឆ្គងតែបន្តិច ក៏ចៀសមិនរួចពីការជាប់គុកច្រវាក់ ឬ ធ្លាក់ខ្លួនជាអ្នកទោសដូចប្រជាជនទាំងនោះដែរ ។ គិតសព្វ ៗ ទៅជីវិតរបស់នាង បានឈានមកដល់ច្រកមួយដែលចង្អៀតបំផុត និង ជិតមាត់រណ្តៅមរណៈបំផុត !

ព្រឹកស្អែកឡើង សម្ផស្សចេញទៅធ្វើការបោសសំអាតនៅមន្ទីររបស់ប្រធានសន្តិសុខ តាមទម្លាប់ធម្មតា ។ ព្រឹកនេះ នាងឃើញប្រធានម៉ាន់ភ្ញាក់ពីព្រលឹម លុបលាងខ្លួនប្រាណ ស្លៀកពាក់ខោ អាវរបបគណៈខ្មៅយ៉ាងស្អាតបាត ហាក់ដូចជាប្រុងចេញដំណើរទៅធ្វើការនៅទីណាមួយ ។ កាលឃើញសម្ផស្សចូលទៅបោសសំអាត នៅក្នុងបន្ទប់ខ្លួន ម៉ាន់ដាក់បង្គួយទៅលើគ្រែ ហើយចាប់សម្លឹងមកមើលនាង ដោយទឹកមុខញញឹម ។ គួរចាប់អារម្មណ៍ថា ម៉ាន់ឃើញសម្ផស្សពេលណា ក៏សំដែងការរួសរាយដែរ ។

- សម្ផស្ស ! . . ឈប់បោសជីសិនទៅ មកណេះមក ខ្ញុំនិយាយនឹងមិត្តបន្តិច !

សម្ផស្សងើបមុខឡើងឃើញម៉ាន់ញញឹម ចោលកែវភ្នែកយ៉ាងមុតមកលើរូបនាង ។ ការញញឹមរបស់គេនេះ ធ្វើឲ្យនាងខ្មាសញ្ញាខ្លួនស្ទើរ ដឹកដៀ . . .

- ចាស លោកពូមានកិច្ចការអីប្រើខ្ញុំ ?

- ទេ គ្មានការអីត្រូវប្រើទេ ខ្ញុំនិយាយរឿងមួយផ្ទាល់ខ្លួន អង្គុយលើកៅអីសិនម៉ោ !

- ចាស ខ្ញុំមិនសមអង្គុយលើគ្រែដំណេកពូទេ ខ្ញុំឈរបានហើយ ! លោកពូមានការអីមានប្រសាសន៍មក !

ម៉ាន់លូកហោប៉ៅអាវ ដកកញ្ចប់បារីម៉ាក " កសិករ " ដែលផលិតពីស្រុកព្រែកឆ្លងមកគោះចេញបារីមួយអុជជក់ ចង្អុយក្លិនថ្នាំក្លាបក្រអូបឈួលឈួលទើបចាប់និយាយ :

- សម្ផស្ស ! . . . ខ្ញុំជាបុរសពោះម៉ាយរស់នៅម្នាក់ឯងលំបាកចិត្តណាស់ !

ម៉ាន់និយាយត្រឹមនេះ អង្គុយនឹករកមិនឃើញឃ្លានិយាយតទៅទៀត. . . ស្ងាត់មួយរយៈ សម្ផស្សក៏សួរឡើង :

- លោកពូ មានឋានៈ ដល់ទៅប្រធានអង្គភាពហើយលំបាកអី ?

- លំបាក នៅម្នាក់ឯង ឈឺក្បាលយប់ព្រលឹមគ្មានអ្នកណាកំដរ . . .



- ខ្ញុំដូចជាមិនយល់សោះពូ មិត្តយើងនៅជុំវិញ ស្ថិតនៅក្រោមទរបស់ពូ ពូត្រូវការហៅប្រើថ្មើរណា បានថ្មើហ្នឹង ! . . . មិត្តយើងគាំពារពូទាំងអស់ !

- មែនហើយសម្ផស្ស ប៉ុន្តែមិនចង់និយាយអញ្ចឹងទេ ! ..ខ្ញុំចង់បានសារនៅនែបនិត្យនឹងខ្លួន ។

សម្ផស្សនៅស្ងៀម ។ ម៉ាន់សម្លឹងមុខនាង ហើយអាងលើអានុភាពស់ខ្លួនក៏និយាយលួកចិត្តនាងភ្លាម :

- សម្ផស្ស . . . ខ្ញុំពេញចិត្តនឹងមិត្តណាស់ បានជាខ្ញុំខំពុះពារយកត្តមកនៅជិតខ្ញុំ . . . បើសិនជាខ្ញុំស្នើមិត្តយកធ្វើជាគ្រួសារខ្ញុំ តើមិត្តល់ព្រមទេ ?

- . . .

- និយាយមកសម្ផស្ស ( ម៉ាន់ពោលសួរម្តងទៀត ) និយាយត្រង់ ៗកុំខ្លាចខ្ញុំអី !

- ចាស ! លោកពូមានវ័យចំណាស់ទៅហើយ ! ខ្ញុំនៅក្មេងមិនក្តិសមជាគ្រួសាររបស់ពូទេ !

- ហ៊ា កុំគិតអញ្ចឹង ! ចាស់ក្មេងស្រេចលើចិត្តស្និទ្ធគ្រទេ ! ខ្ញុំមានឋានៈ ជាប្រធានសន្តិសុខ បានបន្ទន់តវិយោបថទៅទទួលយកមិត្តនារីជាការយល់អត្យាស្រ័យមួយខ្ពស់ណាស់ទៅហើយ ! មិត្តមើលមានមិត្តនារីយើងជាច្រើន បានបេះដូងចិត្តទទួលយកយុទ្ធជនពិការ អង្គការលើកទឹកចិត្តរៀបចំការខ្សម្តង ដប់ ម្តងៗ សប្បាយណាស់មិត្ត ! ឯខ្ញុំមិនមែនជាជន

ភិការ គ្រាន់តែចាស់បន្តិចប៉ុណ្ណោះ មិត្តនារីនៅស្ញូញសាញអី ?

សម្ផស្សបែកញើសស្រិប ៗ ទាំងព្រឺក នឹករកពាក្យដោះសាចំពោះមុខអ្នកមានអំណាចនេះ ។ ម៉ាន់ឃើញនាងឈរទ្រឹង មិនចេញស្តី យល់ថា នាងស្ម័គ្រចិត្តហើយតែអៀនខ្មាសមិនហ៊ានឆ្លើយ ក៏លូកដៃទាញដៃសម្ផស្សឱ្យអង្គុយជិតខ្លួន តែសម្ផស្សរលាស់ចេញយ៉ាងប្រញាប់ ។ ម៉ាន់សើចកក្អៀក ធ្វើជាអ្នកចិត្តធ្ងន់ទ្រាំទ្រក្នុងការចែចង់ :

– កុំភិតភ័យអីណា ! . . . ខ្ញុំមិនរំលោភទេ ព្រោះខ្ញុំចង់បាននារីយកមកធ្វើជាភរិយារបស់ខ្ញុំ ! . . . សម្ផស្សសំរេចចិត្តទៅ ! ខ្ញុំត្រូវទៅធ្វើការនៅតំបន់ ហើយខ្ញុំនឹងស្នើសុំអង្គការរៀបការជាមួយមិត្តដោយត្រឹមត្រូវ ។

– ពូ ( សម្ផស្សនិយាយបង្ហាញហេតុផលមួយទៀត ) ខ្ញុំជានារីមិនអាចនឹងហ៊ានពោលអះអាងថា មិនទទួលយកប្តីមួយអាយុជីវិតនោះទេ ! ប៉ុន្តែពូនិងខ្ញុំមានឋានៈ និងវណ្ណៈភាពខុសប្លែកគ្នា . . . កាលពូយកខ្ញុំចូលធ្វើការ ពូបានឱ្យខ្ញុំសរសេរប្រវត្តិរូបផ្ញើជូនអង្គការ . . . ក្នុងនោះពូបានឃើញច្បាស់ហើយអំពីជីវប្រវត្តិរបស់ខ្ញុំ គឺខ្ញុំជាប្រជាជនដែលភៀសខ្លួនចេញពីតំបន់ខ្មាំង ឬ ក៏ថាប្រជាជនថ្មីក៏បាន . . ឯពូជាអ្នកមូលដ្ឋានចាស់ មានតួនាទីជាកម្មាភិបាលដឹកនាំទៅទៀត . . . អញ្ចឹងធ្វើម៉េចរៀបការជាមួយគ្នាបាន?ពូក៏ធ្លាប់បានលើកឡើងហាមឃាត់ដែរ ។



និយាយចំបញ្ហានេះ ម៉ាន់ចាប់ចងចិញ្ចើមដូចស្វាព្រាម ។ សម្ផស្សរកគន្លឹះមកដោះសា ចំទិសដៅហាមឃាត់របស់អង្គការគេ ។ ម៉ាន់ក្រោកដើរចុះ ដើរឡើង ដៃស្តាំច្រត់លើស្រោមកាំភ្លើងខ្លីនឹករកលៃផ្លូវទៅមុខទៀត ។

– មិនអីទេ ! ( ម៉ាន់បែរមកនិយាយអះអាង ) រឿងនេះស្រេចលើខ្ញុំស្នើអង្គការឱ្យតែមិត្តនារីឆ្លើយថាយល់ព្រមទទួលរូបខ្ញុំចុះ !

សម្ផស្សទៅស្ងៀម ព្រិះរិះរកមធ្យោបាយដោះសាផ្សេងៗទៀត ។

– ម៉េច ? ( ម៉ាន់សួរបង្ខំចិត្ត ) និយាយឱ្យដាច់ស្រេចទៅ !

– ចាស ការរៀបចំគ្រួសារនីមួយៗ មិន អាចសំរេចចិត្តដោយតក់ក្រហល់បានទេ ពិតមែនតែខ្ញុំត្រូវឪពុកម្តាយស្លាប់ចោលអស់ ក៏ប៉ុន្តែសព្វថ្ងៃនៅមានធំរបស់ខ្ញុំជាអាណាព្យាបាលខ្ញុំដែរ ចាំខ្ញុំសួរយោបល់គាត់សិន !

– ហ៎ ! មិត្តនារីមិនទាន់យល់ទេ ! តំណាក់កាលនេះឪពុកម្តាយ ឬ អាណាព្យាបាល គ្មានសិទ្ធិគ្រប់គ្រង ឬ សិទ្ធិសំរេចលើជោគវាសនារបស់កូនចៅទេ ! ស្រេចលើអង្គការ !

– ចាស . . ខ្ញុំមិនហ៊ានប្រឆាំងនឹងអង្គការទេ តែកន្លងមកខ្ញុំធ្លាប់បានច្បាស់ថាអង្គការមិនឱ្យប្រជាជនថ្មី រៀបការនឹងអ្នកមូលដ្ឋានចាស់ទេ បើសិនជារឿងនេះបានសំរេច បានសេចក្តីថាលោកពូជាកម្មាភិបាលតំរូម្នាក់ដែលបានកែប្រែរបបរៀបចំគ្រួសារនៅក្នុងសម័យបដិវត្តន៍នេះ ! ប្រជាជនទាំងអស់រង់ចាំមើល និង ធ្វើតាមលោកពូ , , , ខ្ញុំក៏គោរពតាម

ប្រជាជនដែរ !

- សម្ផស្សនិយាយវ៉ៃមួយផ្លែក្នុងន័យនេះ ធ្វើឲ្យបេះដូងម៉ាន់តឹងស្ទើរប្រេះ គេនៅសង្ឃឹមតែដូចជាសង្ឃឹមចាប់ផ្កាយលើមេឃ ។

- អញ្ចឹង មិត្តនារីដេកត្រិះរិះពិចារណាទៅ! ខ្ញុំទៅធ្វើការនៅតំបន់ ហើយក៏លើកឡើងពិភាក្សាជាមួយអង្គការ ពីបញ្ហាផ្ទាល់ខ្លួននេះដែរ ។

សម្ផស្សដើរចេញមកវិញ ។ ម៉ាន់ទាញក្រមាមករុំ លើកសំពៀតពាក់បញ្ចៀងខ្លួន ប្រុងដើរចេញទៅទាញប៉ូតូផិះ ប៉ុន្តែពេលនោះស្រាប់តែនារីយ៉េតចូលមកដល់ :

- បងប្រធាន គិតទៅណាហ្នឹង ?

- អ៊ុំយ៉េត ខ្ញុំត្រូវទៅធ្វើការនៅតំបន់មួយថ្ងៃ-ពីរ តែល្ងាចមិញភ្លេចប្រាប់មិត្តជាមុន . . .

- ហ៊ី . . . ងាប់ហើយ ! (យ៉េតត្អូញត្អែរ) ម៉្ងៃទៅណេះ ម៉្ងៃទៅណោះ រកពេលពិភាក្សាគ្នាមិនបានសោះ !

- សព្វថ្ងៃ ខ្ញុំជាប់រវល់ការងារច្រើនណាស់ មិត្តមានការអីត្រូវពិភាក្សា ? បើការនោះល្អម ៗ ទុកសិនទៅ !

- ចាស ការងារសំខាន់ដែរ ពីរឿងសំរួលការចាត់តាំងនារី ៗ ធ្វើការនៅក្នុងអង្គភាពយើងនេះ តែបើមិត្តបងប្រញាប់ពេកអញ្ចឹង តើរកនិយាយអីកើត ?



- អ៊ើ . . . កុំអាលឆ្ពោះក្រម៉ាល់ បើការនោះចាំបាច់ និយាយគ្នាសិនក៏បាន ។

- ចាស ចាំបាច់ . . . តែនិយាយទៅយូរពេក ណ្ហើយបើមិត្តបងយល់ព្រមខ្ញុំសួររឿងផ្សេងវិញ ។

- យល់ព្រម និយាយម៉ោ !

- អញ្ចឹងអ្ហ៎? អម្សាញ់មិញមិត្តបងនិយាយរឿងអីជាមួយនារីសម្ផស្ស?

- មានរឿងអី ខ្ញុំហៅមកណែនាំឲ្យចេះធ្វើការទេតើ ។

- កុំបាច់ភូតកុហកខ្ញុំមិត្តបង យ៉េតផ្ដោតកែវភ្នែកសព្រោតទៅលើមុខម៉ាន់ ហើយតម្លើងសំឡេងតឹងបំពង់ក មិត្តបងជាអង្គការដឹកនាំ ហេតុអ្វីបានជាហ៊ានប្រព្រឹត្តអាកប្បកិរិយាមិនគប្បីប្រើសម្ដីឥតអៀនខ្មាស !

ម៉ាន់ចាប់ជ្រួញចិញ្ចើម សួរធ្វើពើ :

- យ៉េត និយាយរឿងអីហ្នឹង ?

- ហ៊ឺះ រឿងអី ! ខ្ញុំមកទីនេះយូរហើយ ខ្ញុំលបស្ដាប់បានដឹងឮទាំងអស់ ! មិត្តបងនិយាយលូកលាន់ទៅលើនាងសម្ផស្សរបៀបណា ?

- និយាយតែផ្ដេសផ្ដាស ! តើបានភស្តុតាងអ្វីខ្លះដែលបញ្ជាក់ថាខ្ញុំប្រព្រឹត្តក្នុងផ្លូវមិនល្អទៅលើនារីសម្ផស្ស ?

- នែ៎មិត្តបង កុំប្រកែក! បើខ្ញុំមានម៉ាញ៉េខ្ញុំនឹងថតទុកជាឯកសារ...

- យ៉េត ! (ម៉ាន់ស្រែកបំបិទមាត់) គ្មានរឿងអីដែលមិត្តនារីឯងមកដឹកឬកដឹកគល់ និងដើររុកគួនខ្ញុំទេ ! រឿងខ្ញុំស្រេចលើខ្ញុំ !

នារីយ៉េតខឹងឆេវ ទ្រាំលែងបាន ក៏ចាប់រំលើកបើកកកាយរឿងខ្លួនយកមកធ្វើជាកម្មវត្ថុ តវ៉ានឹងម៉ាន់ ។

– មិត្តបង ! កុំយកសិទ្ធិប្រធានមកគ្របដណ្ដប់ដើម្បីបិទបាំងចំណុចខ្សោយឬការខ្វះខាតរបស់ខ្លួន ! កន្លងមកមិត្តបងបានស្រឡាញ់ខ្ញុំធ្វើឱ្យខ្ញុំផុងខ្លួន បានលះបង់សេចក្ដីថ្លៃថ្នូរ ដើម្បីមិត្តបង ឥឡូវនេះបងបានបង្វែរមនោសញ្ចេតនាទៅរកនារីសម្ផស្ស ម៉េចប្រុងបំភ្លេចរូបខ្ញុំចោលឬ ? និយាយឱ្យច្បាស់មើល !

កាលបើនារីយ៉េតលើកបញ្ហាខ្លួន មកស្រែកកញ្ច្រោកកញ្ច្រាកបាចដូច្នេះ ម៉ាន់គប់យោបល់ដែរ ព្រោះខ្លួនបានប្រព្រឹត្តប្រាសចាកសីលធម៌ទ្រាំមួយជាមួយនារីយ៉េតក្រមុំចាស់នេះយូរហើយ ។ ម៉ាន់គិតថាបើនឹងនិយាយគ្របសង្កត់បំបិទមាត់នារីយ៉េតតទៅទៀត ច្បាស់ជាកើតទៅជាជម្លោះទាស់ទែងខ្លាំង បណ្ដាលឱ្យដឹងដល់មហាជន ឬ ដឹងដល់អង្គការថ្នាក់លើ ខូចកិត្តិយសខ្លួនមិនខាន ។ ម៉ាន់បែរមកសម្រួលវិញ :

– យ៉េត កុំមាត់ខ្លាំងៗពេក ! រឿងយើងខូចកាចនឹងគ្នា ស្ថិតនៅក្នុងការលួចលាក់ពីភ្នែកប្រជុំអង្គការ មិត្តដឹងទេថាខ្លួនយើងបានប្រព្រឹត្តខុសសីលធម៌បដិវត្ត? យកល្អត្រូវនៅសម្ងំស្ងៀមទៅទើបបានសុខទាំងអស់គ្នា ។

– បានសេចក្ដីថា មិត្តប្រធានឈប់រវល់គិតគូរពីរូបខ្ញុំ ទៅយកនាងសម្ផស្សវិញមែនទេ ? មិត្តប្រធានយល់ទេ នារីសម្ផស្សនោះវាស្ថិតនៅក្នុងសមាសភាពវណ្ណៈបែបណា ?



– បានហើយ ! បើមិត្តដឹងថានារីសម្ផស្សស្ថិតនៅក្នុងសមាសភាពណ្ណៈអាក្រក់ មិនអាច ចុះសម្រុងបាននឹងវណ្ណៈភាពរបស់ខ្ញុំ ម៉េចក៏ហ៊ានចោទប្រកាន់រឿងនេះ ? . . . ឈប់និយាយទៅ ! ខ្ញុំប្រញាប់ឡើងទៅប្រជុំនៅតំបន់ ។

ម៉ាន់ពោលហើយក៏ដើរចេញទៅទាញម៉ូតូធាក់បញ្ឆេះ ឡើងជិះវឹងទៅ ។ នារីយ៉េតដើរមកកាន់កន្លែងធ្វើការរបស់ខ្លួនវិញ ទាំងមុខមិនរីកចេកមិនទុំ ។

ម៉ាន់ឡើងទៅធ្វើការនៅតំបន់ ២០ បានតែមួយថ្ងៃប៉ុណ្ណោះក៏វិលមកវិញ ។ ពេលនោះគេហៅកម្មាភិបាលដឹកនាំបន្ទាប់ពីខ្លួន និងប្រធានផ្នែកទាំងអស់មកប្រជុំប្រកាសប្រាប់ថា ខ្លួនគេត្រូវអង្គការសន្តិសុខតំបន់ហៅឡើងទៅរៀនសូត្រនយោបាយ និងស្ដាប់ផែនការថ្មីមួយរយៈ ។ គេបានប្រគល់កិច្ចការក្នុងមន្ទីរ ឱ្យនារីយ៉េតទទួលខុសត្រូវជំនួសខ្លួន ។ ការដែលម៉ាន់បានលើកឋានៈស្ដីទីឱ្យនារីយ៉េតបែបនេះ យ៉េតក៏មានការសប្បាយចិត្តឡើងវិញ ហើយទទួលយល់ព្រមគ្មានតថមួយម៉ាត់ ។

ក្នុងរយៈកាលអវត្តមានប្រធានម៉ាន់ នារីយ៉េតដែលមានការច្រណែននិន្ទាឈ្នានីស នារីសម្ផស្សស្រាប់ផង ក៏ចាប់ផ្ដើមរិះរកមធ្យោបាយធ្វើបាបមាណវីនេះមួយរំពេច ។ ព្រឹកដែលម៉ាន់ចេញផុតទៅ យ៉េតប្រើនារីសន្តិសុខម្នាក់ឱ្យទៅហៅសម្ផស្សមកជួបនឹងខ្លួន ។

សម្ផស្សដើរចូលទៅ ឃើញទឹកមុខនារីយ៉េតឡើងខ្មៅដូចមរនោះ ព្រួយបារម្ភខុនហើយនឹកថា ប្រធាននារីនេះពិតជាមានគោលបំណងមិនល្អអ្វីមួយត្រូវនិយាយមកលើនាង ។

– សម្ផស្ស ! ចូលមកជិតយើងម៉ោ យើងសួរនារីឯងបន្តិច .. យ៉េតនិយាយក្នុងទឹកមុខស្មើ ។

– ចាស ! . . មិត្តបងមានកិច្ចការអ្វីឬ ?

– មានការណ៍ . . . ចាប់តាំងពីនារីឯងចូលមកនៅអង្គភាពនេះ ខ្ញុំមិនដែលហៅនារីឯងមកចាត់ចែងធ្វើការងារទេ ហើយនារីឯង ក៏ប្រហែលមិនស្គាល់ថាខ្ញុំជាថ្នាក់ដឹកនាំមួយរូបដែរ ។

– ចាសទេ មិត្តបង ខ្ញុំស្គាល់ថាមិត្តបងជាប្រធាននារី . . . ខ្ញុំរង់ចាំតែគោរពតាមបញ្ជាបងប៉ុណ្ណោះ ។

– ស្គាល់ខ្ញុំដែរ ? អញ្ចឹងម៉េចក៏មិត្តឯងធ្វើអាកប្បកិរិយាគោះតើយចំពោះខ្ញុំម៉្លេះ ? មិត្តឯងអាងមិត្តប្រធានយកចូលធ្វើការ និងកាន់ទ្រង់អង់ដំណើរ ! នែ៎ ធ្វើបដិវត្តន៍គ្មានបក្សពួកនិយមទេ !

– ចាស ពុំដូច្នោះទេ ពូប្រធានក៏ខ្ញុំគោរព មិត្តបងក៏ខ្ញុំគោរព ។

– អើ ! បើគោរពខ្ញុំជាប្រធានគ្រប់គ្រងមិត្តឯង ត្រូវស្មោះត្រង់ចំពោះខ្ញុំឥឡូវនិយាយប្រាប់ខ្ញុំ កុំលាក់លៀម ថ្ងៃមុនមិត្តឯងនិយាយការអីជាមួយបងប្រធាន ?



សម្ផស្សអង្គុយនៅស្រឡាំងកាំង នាងងើបមុខឡើងឃើញនារីយ៉េតចោលកែវភ្នែកប៉ុន ៗ ពងមាន់ដាក់ខ្លួន ។

– និយាយម៉ោ ! ( យ៉េតសំឡុតឱ្យឆ្លើយ )

– ចាស . . . គ្មាន

– គ្មានអី បើពេលនោះ គេឃើញនារីឯងច្បាស់ក្រឡែតអង្គុយនៅជិតបងប្រធាន ?

– ចាស គ្មានកិច្ចការអាថ៌កំបាំងអ្វីទេ ខ្ញុំចូលទៅបោសសំអាតកន្លែងធ្វើការរបស់គាត់ជាធម្មតា តែគាត់ហៅខ្ញុំទៅអង្គុយនិយាយលេងហើយណែនាំធ្វើការងារ ។

– មិនបាច់លើកប្រការផ្សេង ៗ មកដោះសារទេសម្ផស្ស គេយកការណ៍ដឹងអស់ហើយថា ការសន្ទនារវាងបងប្រធាននឹងមិត្តឯងក្នុងពេលនោះ វាចូលទៅក្នុងរឿងស្នេហា! ..មិត្តឯងស្រឡាញ់បងប្រធានមែនទេ?

– ចាសទេ ! កុំចោទខ្ញុំអញ្ចឹង !

– បើមិនអញ្ចឹង ម៉េចក៏គេឮនិយាយគ្នាពីរឿងនេះ ?

– គឺ ពូប្រធាននិយាយចេញមកតែពីខ្លួនគាត់ប៉ុណ្ណោះ ។

– ហ៊ឹះ ! បាតដៃតែម្ខាងទះមិនដែលឮ ! . . . មិត្តឯងនេះជាមនុស្សនៅជាប់កំអែលសក្តិភូមិ នាយទុន ! មានគំនិតពុករលួយ មិត្តឯងមិនទាន់បានលត់ដំកសាងខ្លួនរស់នៅតាមរបៀបរបបបដិវត្តន៍ទេ !

តាមចិត្តក្តៅ។ យើងយកនារីឯងទៅដាក់ខ្នោះឥឡូវហ្នឹង តែដោយយល់លើមិត្តប្រធានដែលបានធានាយកនារីឯងចូលធ្វើការ ។

សម្តីចោលដឹងទាំងដងរបស់នារីយ៉េត ពោរពេញទៅដោយហឹង្សាបុគ្គលខ្មោងងឹតនិងអយុត្តិធម៌ជាទីបំផុត ។ នាងគ្មានពាក្យអ្វីអាចតបតទៅវិញបានទៀតឡើយ មានតែការសំរក់ទឹកភ្នែកដោយតូចចិត្តប៉ុណ្ណោះ ។

យ៉េតក្រវែងសម្តីចុងក្រោយថា :

– យើងអនុគ្រោះឱ្យនារីឯងម្តងចុះ ! នារីឯងត្រូវកែប្រែខ្លួន! ចាប់ពីពេលនេះទៅឈប់ជាម្ញូ ឈប់ទៅធ្វើអនាម័យនៅបន្ទប់ប្រធានទៀត យើងចាត់តាំងឱ្យនារីឯងទទួលភារកិច្ចថ្មី : ត្រូវទៅនៅខាងផ្នែកផ្គត់ផ្គង់អ្នកទោស ធ្វើកិច្ចការសព្វមុខក្នុងរោងបាយ ក្រៅពីនេះត្រូវរកបន្លែបបរបាយជ្រូកផង . . . ម៉េចស្តាប់បានទេ !

ចាស . . .

– អើទៅ ! ផ្នែកផ្គត់ផ្គង់អ្នកទោសនៅកន្លែងខាងណោះ ! យកបង្វិចបង្វួរចេញពីមន្ទីរនេះទៅ !

– ចាស . . .

* * *



# ៩

## ស្គាល់តែទឹកភ្នែក

គិតមើលទៅ នាងសម្ផស្សបានមករស់នៅបំរើការងារក្នុងមន្ទីរសន្តិសុខចំនួនបួនខែហើយ ។ ក្នុងរយៈកាលបួនខែនេះ គេបានផ្លាស់ប្តូរភារកិច្ចនាងពីរដង ។ ឥឡូវនាងធ្វើការនៅរោងបាយផ្គត់ផ្គង់អ្នកទោស ។ អ្នកបំរើការងារក្នុងផ្នែកនេះ មិនមានមុខមាត់នឹងគេទេ ភាគច្រើនជាអ្នកមានវិបត្តិផ្សេង ៗ ដែលត្រូវអង្គការគេបញ្ជូនមកលត់ដំកសាងខ្លួន ។

សម្ផស្សមើលសព្វ ៗ ទៅពិចារណាឃើញថា អ្នកធ្វើការទាំងអស់នៅផ្នែកគ្រប់គ្រង និងផ្គត់ផ្គង់អ្នកទោស មានឈ្មោះថាជាបុគ្គលិក កម្មកររបស់អង្គភាពសន្តិសុខមែន ប៉ុន្តែបើនិយាយពីតួនាទី និង សិទ្ធិសេរីភាពគ្មានទេ ។ អ្នកទាំងនេះ ដូចជាសត្វដែលគេប្រោសទុកបើសិនជាអនុវត្តការងារមិនបានសំរេចតាមផែនការរបស់អង្គការ ឬ ក៏ប្រព្រឹត្តអំពើអ្វីមួយខុសឆ្គងនឹងវិន័យ ក៏ចៀសមិនរួចពីការជាប់គុកច្រវាក់ ដូចពួកអ្នកទោសឯទៀត ៗ នោះដែរ ។ ចំណែកជីវភាព កុំថាឡើយអ្នកទោសដែលត្រូវគេកំណត់របបហូបចុកឱ្យក្នុងកំរិតអប្បបរិមា សូម្បីអ្នកធ្វើការ ក៏មានរបបហូបមិនឆ្អែត ។ គេកំណត់ឱ្យរបបហូបរហូត ។ បបរនៅក្នុងសម័យនោះ

មានតែអង្ករមួយគ្រាប់ៗនិងទឹកថ្នាដូចទឹកភ្នែក ប្រៀបធៀបទៅ មិនបា ស្មើនឹងបាយជ្រូកក្នុងពេលបច្ចុប្បន្ននេះផង ។ ការងារពលកម្មចេះតែមា ទម្ងន់ធ្ងន់ធ្ងរឡើង ៗ ឯរបបហូបត្រូវកាត់បន្ថយផាលំផាប់ នេះវិធីលត់ មួយរបស់របបគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ ។ តែទោះបីយ៉ាងណា នាងសម្ផស្សចេះតែស៊ូទ្រាំ អត់ធន់ក្នុងជីវិតរស់នៅដើម្បីកុំឲ្យគេតា ដានមើលឃើញថានាងមិនពេញចិត្ត ចំពោះបដិវត្តន៍គេនោះ ។

រដូវវស្សាឆ្នាំ ១៩៧៧ ភ្លៀងធ្លាក់ជោកជាំដីមានទឹកដក់ល្ហល្ហាចនៅ តាមត្រពាំងបឹងបួរនិងវាលស្រែទាំងនា ។ តិណជាតិទាំងឡាយក៏ដុះលូត លាស់ឡើងខៀវស្រងាត់ ។ ផ្ទៃមេឃហាក់ដូចជាទន់ទាបជាងខែប្រាំង ។ ប្រជាកសិករដែលរស់នៅក្នុងរង្វង់ហ៊ុំព័ទ្ធរបស់សហករណ៍សម្ហាភាពឬកង តូច កងធំ កំពុងចុះសំរុកភ្ជួររាស់ សាបព្រោះដកស្ទូងយ៉ាកមមាញឹកបំផុត។

អង្គភាពសន្តិសុខក៏ធ្វើស្រែភ្ជួរដែរ ហើយជាធម្មតារាល់ថ្ងៃគេបាន ប្រើកម្លាំងអ្នកទោសឲ្យធ្វើការបង្កបង្កើនផល ។ អ្នកទោសនេះមានពីរ បីប្រភេទ អ្នកទោសខ្លះដែលទើបនឹងដោះលែងឲ្យនៅក្រៅឃុំ គេប្រើ ឲ្យធ្វើការនៅជិតៗ មានកងកម្លាំងសន្តិសុខតាមល្បាតអ្នកទោសខ្លះទៀត ដែលត្រូវបានសម្រាលទោសដោះលែងយូរហើយ គេបណ្តោយឲ្យទៅធ្វើ ការនៅទីឆ្ងាយៗ មានសិទ្ធិដើរហើរបានដែរ។ អ្នកនោះត្រូវបានគេទុកចិត្ត ថា លែងមានគំនិតគេចវេះ ឬ រត់លួចចេញពីអង្គភាពនេះទៀតហើយ ។

ព្រឹកថ្ងៃមួយ នាងសម្ផស្សបានចេញទៅបេះបន្លែនៅតាមវាលស្រែ



ម្នាក់ឯងនៅវេលាជិតថ្ងៃត្រង់ នាងបេះបានបន្លែច្រាច់ និងត្រលិតមួយ នលធំ រួចក៏ដើរតាមប្រព័ន្ធភ្លឺស្រែវិលមកកាន់កន្លែងវិញ ។ នាងធ្វើ ណើរមកដល់ទីទួលមួយដែលមានដើមព្រីងមួយដើម ចោលម្លប់ត្រឈឹង ឈៃ ស្រាប់តែនាងភ្ញាក់ព្រើត ! ដោយចោលភ្នែកទៅឃើញរូបអសុភ យទោអង្គុយផ្អែកគល់ឈើ ។ រូបនោះមានរាងកាយស្គមឃើញឆ្អឹងជំនីរ ម្រៀបក្បាលជង្គង់ធំក្រមែង មិនខុសអីពីរូបអសុរកាយ ឬ ប្រេតដែល គូរតាំងនៅតាមជញ្ជាំងព្រះវិហារ ។ បើសិនជានាងសម្ផស្សមាន នៀសរូបិយ ប្រាកដជាយល់ថា ខ្មោចលងហើយរត់ប្រាសយកអាយុ សចទៅហើយ ។ ប៉ុន្តែនាងធ្លាប់បានឆ្លងកាត់ជួបប្រទះសាកសព នុស្សស្លាប់ច្រើនលើករួចមកហើយ នាងគ្មានព្រឺខ្លាចន្តិចបសោះ ។

សម្ផស្សខំសង្កេតមើលរូបនោះមែនទែនទៅ ក៏ស្គាល់ច្បាស់ថា ាបុរសអ្នកទោសម្នាក់ដែលមកធ្វើការភ្ជួររាស់នៅវាលស្រែនេះ ហើយ ស់កម្លាំងមកឈប់សំរាកនៅក្រោមម្លប់ឈើ ។ នាងចាប់ភ្ញាក់នឹកឃើញ ាបុរសនេះ នាងធ្លាប់ឃើញជាញឹកញាប់ នៅក្នុងចំណោមអ្នកទោស សាល ៗ ដែលធ្វើការនៅក្នុងអង្គភាពសន្តិសុខ ប៉ុន្តែនាងពុំដែលជួប ខផ្ទាល់និយាយជាមួយគ្នាទេ ។

សម្ផស្សចូលទៅជិតពិនិត្យមុខបុរសកាន់តែច្បាស់ ហើយនាងហាក់ ដូចជាមានអារម្មណ៍អ្វីមួយ នឹកឃើញថា បុរសនេះមានទឹកមុខប្រហាក់ ប្រហែលទៅនឹងទឹកមុខមនុស្សម្នាក់ ។ សម្ផស្សដាក់កញ្ជើបន្លែបន្ទ ាចាដាស់សតិបុរសឡើង :

- ពូ ! . . . ពូក្រោកឡើង ! មកសម្ងំដេកអីនៅកន្លែងនេះ ?

ប្រហែលជាគេមានការហត់នឿយឬអស់កម្លាំងខ្លាំងណាស់ហើយកំពុងលង់លក់ស្រួលបានជានាងសម្ផស្សបន្លឺហៅហើយមិនព្រមបើកភ្នែក . . ។

- ពូក្រោកឡើង ! មើលក្របី ន៍ ដើរទៅស៊ីស្រូវគេអស់ហើយ !

សម្ផស្សដាស់ស្មារតីបុរសម្តងទៀត ។ បុរសផ្ងារខ្លួនបើកភ្នែកឡើងឃើញយុវនារីនៅទីងមុខ ក៏ទៅជាស្រឡាំងកាំង ។ គេលើកខ្នងដៃជូតភ្នែកមើលស្គាល់ច្បាស់ថា នារីនេះជាអ្នកធ្វើការនៅមន្ទីរសន្តិសុខ ក៏ចាប់ភិតភ័យមួយរំពេច ។ ក្នុងអារម្មណ៍របស់គេផ្តោតថា នារីនេះប្រាកដជាមកតាមដានខ្លួន . . . ។ ក្នុងពេលលក់រលើរ ៗ អម្បាញ់មិញគេបានឮសំឡេងនារីប្រាប់ថា !... " ក្របីស៊ីស្រូវ " គេប្រុងស្ទុះទៅមើលក្របី តែសម្ផស្សពោលឃាត់ !

- អើពូ ! .. ខ្ញុំកុហកទេណា៎ ក្របីនៅស៊ីស្មៅក្នុងស្រែជិតនេះទេ ពូអង្គុយស្រួលបួលវិញមក ។

- បាទ . . អរគុណមិត្តនារីដែលបានមកដាស់ស្មារតីរបស់ខ្ញុំ ... មិត្តនារីអញ្ជើញមកទីនេះមានការអីដែរ ?

- ចា៎ស មកបេះបន្លែទៅដាក់រោងបាយ ។

បុរសធ្វើមុខជូរ :

- ហ៊ឺ . . . ថ្ងៃណាស់ទៅហើយ បន្លែនៅឯណោះ អង្កាល់បានយកទៅស្ងោរហូប ?



- ចា៎ស ព្រឹកនេះមានម្ហូបហើយ ខ្ញុំរកបន្លែទុកសំរាប់ពេលល្ងាចទេតើ . . . និយាយអញ្ចឹង ពូឃ្លានបាយណាស់ហើយមែនទេ ?

- បាទ ឃ្លានដែរ . . . ប៉ុន្តែមិនទាន់ហ៊ានទៅហូប នៅមើលក្របីឲ្យស៊ីស្មៅឆ្អែតសិន ។

- ពូមកធ្វើការទីនេះតែម្នាក់ឯងទេឬ ?

- បាទគេឲ្យខ្ញុំមកភ្ជួរបង្ហើយស្រែនេះតែម្នាក់ឯងទេ ក្រុមអ្នកទោសដទៃទៀត នៅភ្ជួរស្រែខាងណោះ !

- ពូចេះអត់ធ្មត់ទ្រាំលំបាកក្នុងការងារ និងគោរពអង្គការវិន័យបានល្អណាស់ !

- បាទ បើខ្ញុំមិនខំតស៊ូធ្វើការ និងសម្តែងការស្មោះត្រង់នឹងអង្គការទេ ប្រហែលជាអង្គការមិនទុកចិត្តបណ្តែតបណ្តោយឲ្យខ្ញុំដើរធ្វើការឆ្ងាយ ៗ តែម្នាក់ឯងបែបនេះទេណា៎នារី ។

- ចា៎ស ! . . ខ្ញុំសូមសួរពូបន្តិច ពូមានរឿងអីបានជាមកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខនេះ ? . . ជាប់ពីឆ្នាំណាមក ?

កាលឮសម្ផស្សសួរដូច្នេះ បុរសក៏ងើបមើលមុខនាងចំ :

- ហ៊ឺ ... រឿងខ្ញុំវែងឆ្ងាយណាស់ . . ខ្ញុំជាប់ឃុំពីឆ្នាំ១៩៧៥មក..

បុរសនិយាយដាច់ឃ្លាត្រឹមនេះ ព្រោះនឹកឃើញក្រែងរអែងថា នារីនេះជាភ្នាក់ងារសន្តិសុខមកតាមដានយកការណ៍ពីខ្លួន ។ គេយកដៃជ្រែងសក់ស្កូញស្កាញ អេះក្បាលព្រមទាំងទម្លាក់ទឹកមុខទៅវិញ ។

ខណៈនោះនាងសម្ផស្ស ដែលមានការមន្ទិលសង្ស័យ រង់ចាំពិនិត្យមើលលក្ខណៈភិនភាគ ក៏ឃើញច្បាស់ប្រជ្រុយក្រហមប៉ុនចុងធូបលេចនៅក្រោមទងត្រចៀកស្ដាំរបស់មាណព ។

សម្ផស្សបន្ទឺស្ទួរភ្លាម :

. ពូ . . . ពូឈ្មោះអីដែរ ?

– បាទ . . ជំរាបមិត្តនារីតាមត្រង់ នាមដើមរបស់ខ្ញុំឈ្មោះបូរិន្ទ តែសព្វថ្ងៃគេហៅខ្ញុំថា " រិន្ទ ។ " ។

បូរិន្ទ ! . . បងបូរិន្ទ !

សម្ផស្សឧទានឡើង ស្រាប់តែគាំងបេះដូងហាក់ដូចជាមនុស្សមានជម្ងឺខ្យល់គ ។ នាងឈរធ្មឹង សម្លឹងមុខបូរិន្ទមួយសន្ទុះ ក៏រលំដួលស្រូសទៅលើទ្រូងបុរស ។ ពេលនោះទឹកភ្នែកក្តៅគគុកក៏ធ្លាយចេញមកហូរស្រោចស្រពជាមួយនឹងវាចាដ៏ញាប់ញ័ររន្ធត់ :

– បងបូរិន្ទ . . បងអើយ! ខ្ញុំមិនបានទឹកគិតសោះថា បងនៅរស់ទេ

បូរិន្ទក៏អញ្ចឹងដែរ ទៅជាស្រឡាំងកាំងអស់ពីរ បីនាទី ។ ពេលនោះបេះដូងរបស់គេដែលស្ងិតស្រពោនយូរហើយ ហាក់ដូចជាមានវេទមន្តអ្វីមួយចូលមកអង្រួនធ្វើឱ្យរំភើបឥតឧបមា ។ បូរិន្ទស្ទើរតែមិនជឿថារូបកាយនេះ សំឡេងនេះ គឺនាងសម្ផស្សជាប្រពន្ធកំសត់របស់ខ្លួនដែលបានព្រាត់ប្រាសអស់រយៈកាលប្អូនប្រាំឆ្នាំមកហើយនោះទេ ។ បូរិន្ទក្រសោបនាងឡើងសម្លឹងមុខ :



– អូនគឺ . . គឺសម្ផស្សមែនទេ ?

– ចាស ខ្ញុំសម្ផស្ស

– សម្ផស្ស! . . បូរិន្ទពោលអួលដើមក និងចេញទឹកភ្នែករលីងរលោងបងក៏អញ្ចឹងដែរ គ្មានទឹកស្មានសោះ ថាអូនមានជីវិតរស់នៅ ហើយយើងត្រូវបានជួបមុខគ្នាឡើងវិញទេ ។

សម្ផស្សយំសោករៀបរាប់ :

– ចាស . . . បងបូរិន្ទអើយ ! ខ្សែជីវិតយើងទាំងពីរនាក់ធ្លាក់ចុះក្នុងស្ថានភាពវេទនាអីយ៉ាងនេះបង . . ខ្ញុំមើលបងមិនស្គាល់ ព្រោះបងស្គមទៅតែស្បែកដណ្ដប់ឆ្អឹង !

– បងក៏មើលអូនមិនស្គាល់ដែរ ពីមុនអូនមានរូបរាងកាយស្អាតសក់វែងអន្លាយ ឥឡូវនេះសក់អូនខ្លីក្រឡឹងក មើលទៅដូចជានារីវ័យកណ្ដាលទៅហើយ ។

– ចាស បងក្តី ខ្ញុំក្តី សុទ្ធតែប្រែរូបសម្ផស្សអស់រលីង ! នេះគឺឧបកម្មជាប្រជាធិបតេយ្យរបរិតណ៌ាបង !. . បង សូមបងនិយាយប្រាប់ខ្ញុំមើល កាលយន្តហោះទម្លាក់គ្រាប់បែកនៅកោះកែរនោះ ហេតុយ៉ាងម៉េចបានជាបងនៅរស់ ? ហើយមានរឿងយ៉ាងណាដែរបានជាបងត្រូវមកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខនេះ ?

បូរិន្ទពិនិត្យមើលសភាពការណ៍នៅជុំវិញខ្លួន ទើបងាកមកកំណាលរឿងប្រាប់ប្រពន្ធ :

-អូន កាលណោះបងនៅចាំបាន ក្នុងខែ ៧ ឆ្នាំ១៩៧៣ យើងត្រូវព្រាត់គ្នាដោយសារយន្តហោះទម្លាក់គ្រាប់បែករបស់ចក្រពត្តិអាមេរិក ។ ពេលនោះ បងបាននាំអូនរត់រកកន្លែងក្រាបនៅច្រាំងទន្លេជិតភូមិកោះកែវ គ្រាប់បូមរបស់យន្តហោះប៊េ៥២ បានធ្លាក់នៅក្បែរបង បងមិនដឹងថាព្រឹត្តិការណ៍នោះវិវឌ្ឍន៍ទៅបែបណាទេ . . . ស្រាប់តែបងភ្ញាក់ស្មារតីឡើងដឹងខ្លួនបងនៅជាមួយនឹងគំនរដីដែលជះទៅឯមាត់ទឹក បងខំលូនឱបគល់ឈើមួយ ហើយខំស្រែកហៅរកអូន តែពេលនោះដោយត្រចៀកបងហ៊ឹងគ្មានដឹងអ្វីទាំងអស់មិនដឹងថា បងស្រែកនោះឮឬមិនឮទេ ។ គល់ឈើដែលបងតោងនោះរេះតែរំកិលចេញផុតពីច្រាំងហើយក៏អណ្តែតតាមទឹកហូរចុះមកក្រោម ។ នៅពេលថ្ងៃជិតត្រង់ បងបានជួបនឹងប្រជាជនម្នាក់ ធ្វើដំណើរតាមទូកកាត់ទន្លេមេកុង ។ ប្រជាជននេះបានស្រង់បងយកមកផ្ទះរបស់គាត់នៅភូមិ ជាទីស្រុកពាមរក៍ ។ គាត់ឈ្មោះ សំ ភរិយារបស់គាត់ឈ្មោះសយ ។ ថ្ងៃក្រោយមក ដោយមានសង្គ្រាមផ្ទុះឡើងយ៉ាងខ្លាំងនៅក្នុងស្រុកពាមរក៍ ពូសំ មីងសយមិនអាចទ្រាំទ្រនៅបាន ក៏បាននាំបងភៀសខ្លួនមកនៅភូមិធាយ ក្នុងស្រុកបាភ្នំ ។

ថ្ងៃមួយមានប្រជាជនម្នាក់ធ្វើដំណើរទៅពីស្រុកមេសាង គេបាននិយាយថា គេស្គាល់ឈ្មោះ ពូភួន និងកូនស្រីរបស់គាត់ឈ្មោះ សម្ផស្សភៀសខ្លួនចេញពីទន្លេធំ មកនៅតំបន់រំដោះ ដោយមូលហេតុសង្គ្រាម ។



ទទួលបានដំណឹងនេះ បងនឹកសង្ស័យថា រូបអូននៅរស់ ... បងនឹកអូនណាស់ ! ហើយចង់ដឹងការពិត មានគោលបំណងចង់ស្វែងរករូបអូន ប៉ុន្តែរដ្ឋអំណាចមូលដ្ឋានគេហ៊ុំព័ទ្ធមិនឱ្យបងមានសិទ្ធិសេរីដើរហើរបានឡើយ ។

ដល់ក្រោយថ្ងៃជ័យជំនះ ១៧ មេសា មានប្រជាជនទីក្រុងជាច្រើនដែលត្រូវអង្គការគេជម្លៀសមកកាន់មូលដ្ឋាន។ ឆ្លៀតឱកាសដែលគេកំពុងធ្វើដំណើរហូរហែបងក៏លាពូសំមីងសយចេញធ្វើដំណើរស្វែងរកអូនដែរ។ ប៉ុន្តែចៃដន្យ ! គ្រាន់តែចូលដល់ដីស្រុកមេសាងស្រាប់តែរដ្ឋអំណាចមូលដ្ឋានគេចាប់រូបបងតែម្តង ។ បងគ្មានសំបុត្រមួយបន្ទាត់សោះត្រូវគេចោទថា " សន្តិសម្ព័ន្ធ " (១) ស៊ើរុងផ្ទៃក្នុង ហើយក៏បញ្ជូនខ្លួនទៅមន្ទីរសន្តិសុខស្រុក ។ បងត្រូវជាប់គុករហូតមក ទើបនឹងអង្គការគេដោះលែងឱ្យនៅក្រៅឃុំ កាលពីដើមឆ្នាំ ១៩៧៧ នេះ ។

ចំណែកគ្រួសារពូសំ មីងសយ បងមិនដែលបានទទួលដំណឹងពីការរស់នៅរបស់គាត់ឡើយ ។

ក្នុងឱកាសដែលបុរិន្ទរៀបរាប់រឿងជីវិតខ្លួន នាងសម្ផស្សអួលណែនក្នុងឱរាអាណិតប្តីឥតអ្វីប្រៀប ។ នាងយកក្រមាជូតទឹកភ្នែកផាញឹកញាប់និងខំបន្លឺវាចាឡើងថា :

---

(១) អ្នកធ្វើចលនាសម្ងាត់ប្រឆាំងបដិវត្តន៍សម័យនោះ ។

- ចា៎ស បង យើងទាំងពីរនាក់បានឆ្លងកាត់រាល់ឧបសគ្គនិងភ្លើងសង្គ្រាមរត់ចេញពីតំបន់ខ្មាំង មកកាន់តំបន់រំដោះ សង្ឃឹមថានឹងត្រូវបានរដ្ឋអំណាចបដិវត្តគេនេះទទួលស្គាល់ ផ្តល់អាទិភាពឱ្យរស់នៅបានសុខសាន្ត តែផ្ទុយទៅវិញ សេចក្តីសង្ឃឹមទាំងអស់នោះត្រូវរលាយសាបសូន្យ មានតែការងាររទុក្ខវេទនា និងតំណក់ទឹកភ្នែក !... រឿងខ្ញុំក៏ជួបនឹងសភាពប្រែល្វីងជូរចត់ដូចបងអញ្ចឹងដែរ ពេលណាមួយឱកាសល្អខ្ញុំនឹងជំរាបដំណើររឿងពិតប្រាប់បង ។

បុរិន្ទយល់ថា ឱកាសនេះ នាងសម្ផស្សគ្មានពេលនឹងសំណេះសំណាលជាមួយខ្លួនបានយូរទេ ព្រោះស្ថិតនៅក្នុងដំណាក់កាលចង្អៀតដូចគូថម្ជុល គេក៏សួរបញ្ជាក់ទៅលើរឿងផ្សេងៗវិញ :

- អូន បើអញ្ចឹង អូនបានមកធ្វើការនៅមន្ទីរសន្តិសុខនេះយូរហើយឬ ?

- ចា៎ស ទើបនឹងគេហៅមកធ្វើការនៅក្នុងដើមឆ្នាំនេះដែរ ។

- បងសុំសួរចិត្តអូនបន្តិចចុះណា៎ ( បុរិន្ទពោលសម្លឹងក្នុងកែវភ្នែកសម្ផស្ស ) សព្វថ្ងៃអូនបានរក្សាខ្លួននៅដដែល ឬ បានកសាងគ្រួសារថ្មីទៀតហើយ ?

ឮបុរិន្ទសួរបែបនេះ សម្ផស្សឱនមុខយំម្តងទៀត ។ បុរិន្ទខ្លាចនាងមិនហ៊ានឆ្លើយក៏ពោលបង្ហាញពីចិត្តថ្លើមរបស់ខ្លួន :



- អូននិយាយប្រាប់បងដោយត្រង់មក បើទុកណាជាអូនមានគូស្រករថ្មីទៀតហើយ ក៏បងមិនតូចចិត្តដែរ...

- បងបុរិន្ទអើយ !.. ម៉េចបងសួរអូនអញ្ចឹង ?

- ព្រោះបងគ្មានអ្វីជាលំអជីវិតទៀតទេ !

- ខ្ញុំបានសច្ចាហើយថា ខ្ញុំស្មោះត្រង់នឹងបងរហូតមួយជីវិត ! ខ្ញុំ
នទទួលយកបុរសណាជាប្តីក្រៅពីរូបបងជាដាច់ខាត ! ទោះបីបងស្លាប់
ក៏ខ្ញុំស៊ូទ្រាំនៅម្នាក់ឯងរហូតអាយុខ័យ ។

- ឱ ! បងរំភើបនឹងទឹកចិត្តភក្តីភាពរបស់អូនណាស់ !. តែឥឡូវ
ះសេចក្តីស្នេហារបស់យើងប្រៀបដូចជាយល់សប្តិ ឬ ជាស្រមោល
លឃើញរូបហើយចាប់មិនបាន . . . អូនយល់ហើយបងជាអ្នកទោស
នជាអ្នកធ្វើការនៅក្នុងអង្គភាព យើងរស់នៅបានត្រឹមតែឃើញមុខគ្នា
ណ្ណោះ របបគេមិនឱ្យយើងជួបជុំគ្នាទេ ! បងក៏អស់សាច់ឈាមធ្វើជា
របស់អូនតើតដែរ អញ្ចឹងបានជាបងនិយាយថា បើរូបកាយអូនក្លាយជា
បស់អ្នកដទៃ ក៏បងមិនអន់ចិត្តដែរ ។

- ឈប់និយាយទៅបង សេចក្តីសុខរបស់ខ្ញុំមិនមែនស្ថិតលើខ្ញុំបាន
សាងគ្រួសារថ្មីក្នុងរបបនេះទេ !. ខ្ញុំបានឃើញបងមានជីវិតរស់នៅតែ
ណ្ណោះ ខ្ញុំមានសេចក្តីសុខនៅក្នុងជីវិតហើយ !

- ឱស ! បងសប្បាយចិត្តណាស់ ! ទោះបីក្នុងតំណក់ទឹកភ្នែក
យើងទ្រាំតស៊ូទៅទៀត. .អញ្ចឹងអូនវិលទៅអង្គភាពវិញចុះណា៎ ពេល

វេលានេះចង្អៀតណាស់ សូមថែរក្សាការសម្ងាត់លាក់រឿងយើងកុំឲ្យពួកគេដឹង !..

- ចាស !...

*

*   *

ពេលម៉ាន់បានចេញពីវគ្គរៀនសូត្រនៅតំបន់ ម៉ាន់បានវិលមកកាន់តំណែងជាប្រធានសន្តិសុខដដែល ។ ម៉ាន់ក្តាប់សភាពការណ៍គ្រប់គ្រងនៅក្នុងមន្ទីរ បានដឹងថា នារីយ៉េតបានផ្លាស់ប្តូរភារកិច្ចនារីសម្ផស្សទៅខាងផ្នែកគ្រប់គ្រង និងផ្គត់ផ្គង់អ្នកទោស គេមានសតិអារម្មណ៍ស្តាយដែរ ព្រោះគេមានគោលបំណងការពារនារីនេះ ដើម្បីផលប្រយោជន៍ខាងមនោសញ្ចេតនារបស់ខ្លួន ។

ក៏ប៉ុន្តែពេលនោះ មានលេចរឿងហេតុដ៏អាស្រូវ កើតឡើងដោយគំនិតនារីយ៉េត ។ យ៉េតបានឲ្យភ្នាក់ងារសន្តិសុខនារី តាមដានសកម្មភាពនាងសម្ផស្សរៀងរាល់ថ្ងៃ ។ ការទាក់ទងមនោសញ្ចេតនាប្រពន្ធ ប្តីរវាងនាងសម្ផស្សនិងប៊ូរិន្ទ យូរៗទៅធ្វើឲ្យមហាជនជុំវិញ មានការចាប់អារម្មណ៍ថា អ្នកទាំងពីរនេះ មានទំនាក់ទំនងស្គាល់គ្នាច្បាស់ ។ មិនយូរប៉ុន្មាន ក៏មានរបាយការណ៍សម្ងាត់ទៅដល់ម៉ាន់ លើកឡើងបង្ខូចកិត្តិយសនាងសម្ផស្ស ។

ម៉ាន់បានហៅនាងសម្ផស្សទៅសាកសួរមួយរំពេច :

- សម្ផស្ស ! ( ម៉ាន់ពោលឡើងក្នុងទឹកមុខបរិហាក់ដូចជាមានបង្កប់កំហឹង ) យើងស្តាយណាស់ ! កន្លងមកយើងបានខិតខំយកចិត្តទុកដាក់បំពាក់បំប៉នគោលជំហរ សតិអារម្មណ៍នារីឯងឲ្យធ្វើការល្អ ដើម្បីកសាងខ្លួនទៅជាកម្មាភិបាលនារីម្នាក់ ថែមលើសនេះ យើងមានគោលបំណងស្នើនារីឯងយកធ្វើជាគ្រួសារយើងទៀត មិនគួរណានារីឯងហ៊ានប្រព្រឹត្តខុសវិន័យអង្គការ ..

សម្ផស្សឈរស្រឡាំងកាំង នឹកឃើញថាម៉ាន់ប្រាកដជាបានដឹងរឿងរ៉ាវរបស់ខ្លួនហើយប្រុងចាប់ផ្ទាក់ប្រកាន់ទោស ។ នាងខំតាំងចិត្តក្លាហានហ៊ានតស៊ូប្តូរសក្តិជាមួយម៉ាន់វិញ :

- ពូប្រធាន! ខ្ញុំមិនយល់ថា តើពូប្រធានចង់និយាយស្តីឲ្យខ្ញុំពីរឿងអ្វីទេ ?

- សម្ផស្ស ! មិត្តនារីឯងមិនមែនកូនក្មេងបៀមដៃ មិនយល់ដឹងពីអំពើប្រាសចាកសីលធម៌ដែលមិត្តឯងបានប្រព្រឹត្តនុះទេ !.. នារីឯងបានទាក់ទងនឹងអាអ្នកទោសឈ្មោះ រិន្ទ ប៉ុន្មានដងហើយ ! និយាយពីរឿងអ្វីខ្លះ ? ហ៊ឺះ ចង់មិត្តឯងធ្វើអ្វីក៏យើងដឹងដែរ អង្គការមានភ្នែកដូចម្នាស់ ! ឥឡូវសម្តែងការស្មោះត្រង់មើល !

- ពូប្រធាន ·.. អ្នកណារាយការណ៍ថាខ្ញុំទាក់ទងស្រឡាញ់អ្នកទោសនោះមិនពិតទេ !

- មានពិត បានជាគេនិយាយ ! គេថាអ្នកទោសឈ្មោះ រិន្ទនិងនារីឯងពិតជាស្រឡាញ់គ្នា !

- ហ៎ា ពូប្រធានយល់ច្រឡំហើយ ! សម្ពស្សបន្ទីដោះសាក្នុងទឹកមុខញញឹម គេនិយាយបែបនោះគ្មានសមហេតុផល តាមធម្មតាខ្ញុំនៅរោងបាយផ្គត់ផ្គង់លែងអីមានស្គាល់ឈ្មោះអ្នកទោស រឿងអ្នកទោសឈ្មោះវិន្ទនោះ ខ្ញុំមានគោលបំណងមកជំរាបពូប្រធានយូរហើយ ប៉ុន្តែតាំងពីពូវិលពីតំបន់វិញ ខ្ញុំឃើញពូមានការងាររវល់ច្រើនពេក ការពិតអ្នកទោសឈ្មោះវិន្ទនោះត្រូវជាបងប្អូនជីដូនមួយរបស់ខ្ញុំទេតើ គ្រួសារគាត់និងគ្រួសារខ្ញុំត្រូវបែកគ្នាក្នុងសង្គ្រាមវាយចក្រពត្តិអាមេរិក ខ្ញុំទើបនឹងមកឃើញគាត់នៅកន្លែងនេះ បើមិនជឿហៅគាត់មកសួរចុះ !.. ខ្ញុំបាននិយាយនឹងគាត់គ្មានរឿងអ្វីក្រៅពីទំនាក់ទំនងក្នុងមនោសញ្ចេតនាបងប្អូនទេ ។

- ហ៎ាក ! ម៉ាន់លាន់មាត់ហើយប្រែមុខស្រួលមកវិញបន្តិច ឈ្មោះវិន្ទនោះត្រូវជាបងមិត្តនារីឯង ?

- ចា៎ស

- អញ្ចឹង យូរហើយ ម៉េចក៏មិត្តឯងមិននិយាយប្រាប់ខ្ញុំ ?

- ចា៎ស ខ្ញុំខ្លាចផង ... ខ្លាចពូរើសទាល់ចិត្តផង ព្រោះពូបានប្រកាសថា មិនឱ្យអ្នកធ្វើការរាប់រកអ្នកទោស ទោះជាសាច់ញាតិក៏ដោយ ! ពូធ្លាប់និយាយថា សក់អ្នកណាក្បាលអ្នកហ្នឹង !

ម៉ាន់ចាប់សើចញឹម ៗ :



- នោះ ជាគោលការណ៍របស់អង្គការ ! តែចំពោះសម្ពស្សដែលនៅធ្វើការជាមួយខ្ញុំអញ្ចឹង ខ្ញុំក៏មានការយោគយល់ខ្លះដែរ ។

- ចា៎ស សម្ពស្សនិយាយចាក់បណ្តោយ ខ្ញុំយល់ថា លោកពូជាមនុស្សចិត្តល្អ មានការអធ្យាស្រ័យដ៏ច្រើន បើពូរាប់អានខ្ញុំ គួរតែអនុគ្រោះប្រណីដល់បងខ្ញុំផង ។

- មិនអីទេសម្ពស្ស ( ម៉ាន់ទន់ចិត្តថ្លើម ; វិន្ទ បងរបស់មិត្ត ខ្ញុំបានសម្រាលទោសដោះលែងឱ្យនៅក្រៅឃុំជិតមួយឆ្នាំមកហើយ ឥឡូវនេះគេទុកចិត្តឱ្យដើរធ្វើការឆ្ងាយៗ មានសិទ្ធិប្រហាក់ប្រហែលអ្នកធ្វើការដែរ! ថ្ងៃមុខទៅបើគោលជំហរ សតិអារម្មណ៍កាន់តែល្អ ខ្ញុំនឹងឱ្យទៅនៅមូលដ្ឋានវិញ ឬធ្វើការនៅទីនេះតែម្តង ព្រោះទៅកន្លែងណាក៏ធ្វើពលកម្មដូចតែគ្នាទេ ។

សម្ពស្សនឹកឃើញវែងឆ្ងាយឆ្លើយឱ្យម៉ាន់កាន់តែកក់ក្តៅ :

- ចា៎ស តាមមើលទៅ គាត់ពុំដឹងទៅទីណាទេ ព្រោះក្រុមគ្រួសារឪពុកម្តាយស្លាប់អស់ហើយ ដូចខ្ញុំដែរ សុំផ្ញើជីវិតនៅបំរើអង្គការតែម្តង ។

- មិនអីទេ ចាំខ្ញុំជួយដោះស្រាយ ... ចាប់ពីពេលនេះទៅ ខ្ញុំនឹងផ្តល់របបហូបចុកឱ្យបានគ្រប់គ្រាន់ណា៎ ។

- ចា៎ស អរគុណ !

សម្ផស្សបន្ទឹទាំងញញឹម ធ្វើឱ្យម៉ាន់រឹតថ្លើមប្រមាត់ ។ នាងលាចេញទៅប្រកបការងារវិញ ។

ពេលដែលសម្ផស្សចេញផុតបន្តិចមក គេឃើញនារីយ៉េតដើរចូលទៅក្នុងកន្លែងធ្វើការរបស់ម៉ាន់ ។ យ៉េតឃើញម៉ាន់អង្គុយសរសេរនៅតុ មិនងើបឡើងនិយាយរាក់ទាក់រកខ្លួន ក៏មានអារម្មណ៍ខ្មាះខ្នរចាប់ស្លុះឡើង ទាំងសម្តីរឹងកំព្រឹស :

- ម៉េច ! មិត្តបង ហៅនាងសម្ផស្សនោះធ្វើការហើយឬនៅ ?

- ហៅធ្វើការហើយ !.. ម៉ាន់និយាយកំបុតកំបុយ ដោយមិនយកចិត្តទុកដាក់ ។

- បើហៅធ្វើការហើយ តើមានវិធានការយ៉ាងណាដាក់លើរូបវាទេ ?

- វិធានការស្អី ?

ម៉េចនិយាយអញ្ចឹង ! សេចក្តីរាយការណ៍របស់ខ្ញុំ ថាវាខុសសីលធម៌នឹងគ្នា តើមិត្តបងបានពិនិត្យពិចារណា និងមានគោលការណ៍អប់រំវាទេ ?

- មិត្តឯងនិយាយផ្តាស ! មិត្តឯងចង្អួចកិត្តិយសគេជានារីភេទដូចមិត្តឯងដែរ ! ការពិត គេត្រូវជាបងប្អូននឹងគ្នា !

- បងប្អូនហ៎ះ !.. ហ៊ុះបើទុកជាបងប្អូន ក៏មិត្តបងត្រូវតែវិនិច្ឆ័យដោះ



ស្រាយចេញវត្តមានរបស់នារីសម្ផស្សពីអង្គភាពដែរ គឺជាក្រិត្យក្រមមួយមិនអាចទុកបាន ចំពោះអ្នកធ្វើការដែលជាប់សមាសភាពខ្មាំង !

- ឈប់និយាយ ! (ម៉ាន់ក្រោកឡើងគំហក) មិត្តឯងប្រុងធ្វើបដិវត្តន៍នេះតែម្នាក់ឯងឬ ? មិត្តឯងមានទស្សនៈចង្អៀតចង្អល់ពេកហើយ!

- ចា៎ស ! មិត្តបងមានមតិនេះត្រូវតែមួយជ្រុងប៉ុណ្ណោះ ! ប៉ុន្តែមិត្តបងភ្លេចធាតុដើមនៃវណ្ណៈខ្លួន និងមិនអនុវត្តរបបប្រធានសន្តិសុខរបស់រដ្ឋអំណាចកម្ពុជាប្រជាធិបតេយ្យ !

- មិត្តយ៉េត កុំប្រើទ្រឹស្តីមាំៗដាក់ខ្ញុំពេកណា៎ះ ! ក្នុងតួនាទីខ្ញុំជាប្រធាន ខ្ញុំមានសិទ្ធិគ្រប់គ្រងក្នុងការសំរេចរាល់បញ្ហា តែរឿងនេះវាគ្មានជារឿងអីត្រូវខ្ញុំដោះស្រាយខ្ញុំយល់ហើយ សម្តីរបស់មិត្តឯងនិយាយមកចង់កំចាយនារីសម្ផស្ស ហ៊ុះ ! ស្មានថាខ្ញុំមិនដឹងឬ មិត្តឯងបានធ្វើអ្វីខ្លះរាំងស្ទះដល់គោលបំណងរបស់ខ្ញុំ នៅពេលដែលខ្ញុំធ្វើពាក្យសុំនិងប្រវត្តិរូបស្នើឡើងអង្គការស្រុកនិងតំបន់ ដើម្បីសុំរៀបគ្រួសារជាមួយនាងសម្ផស្សមិត្តឯងបានទៅខ្ទាស់មិនឱ្យអង្គការសំរេច ។

- ការពិត គឺអង្គការមិនសំរេចតែម្តង ! មិត្តប្រធានកុំយល់ថាខ្ញុំដើរទៅជ្រៀតជ្រែកក្នុងរឿងនេះ !

យ៉េតបោះសម្តីហើយ ក៏ដើរចេញទៅវិញទាំងមួម៉ៅក្តៅក្រហាយ ។

*

*　　*

ចុងរដូវវស្សាឆ្នាំនោះ អង្គភាពសន្តិសុខបានលើកផែនការទៅរកឈើនិងឫស្សីនៅក្នុងតំបន់ ២១ ដើម្បីយកមកធ្វើសំណង់ក្នុងស្រុក ។ គេបានជ្រើសរើសចាត់តាំងមនុស្សមួយចំនួន ឲ្យនៅប្រចាំការកាប់ឈើព្រៃនោះ ។ អ្នកដែលត្រូវទៅ មានកម្លាំងសន្តិសុខប្រាំនាក់ និងអ្នកទោសស្រាល ៗ ដែលគេមានទំនុកទុកចិត្តចំនួន ដប់ប្រាំនាក់ ។ ក្នុងចំណោមនោះ បុរិន្ទក៏ត្រូវគេចាត់តាំងឲ្យទៅធ្វើការជាមួយគេដែរ ។

ព្រឹកដែលបុរិន្ទចេញដំណើរ នាងសម្ផស្សបានឆ្លៀតឱកាសទៅជួបទាំងព្រលឹម ។ បុរិន្ទស្នាក់នៅក្នុងខ្ទមចាំក្របី ស្ថិតនៅមិនឆ្ងាយប៉ុន្មានពីរោងបាយសមូហភាពរបស់អ្នកទោស ។ នេះទើបនឹងក្រោកពីដំណេកហើយរៀបចំបង្វេចបង្វរ ដែលមានខោអាវកញ្ចាស់កន្ទុំតែមួយប្រដាប់ក្រៅពីស្លៀកជាប់នឹងចង្កេះ ។ កាលឃើញនាងសម្ផស្ស ដើរចូលទៅទាំងព្រហែបព្រហប បុរិន្ទពោលៈឡើង :

- ឱ ! អូនសម្ផស្ស ...
- ចាំសបង បងរៀបចំចេញដំណើរទៅឥឡូវនេះឬ ?
- ហ្នឹងហើយអូន ភ្លឺច្បាស់ បងចេញដំណើរហើយណ៎ា
- គេឲ្យបងទៅធ្វើការដល់ណា ?
- គេចាត់តាំង ឲ្យបងទៅកាប់ឈើហ៊ុប នៅក្នុងព្រៃស្រុកទឹកជ្រៅតំបន់២១ខាងជើងថ្នល់ជាតិលេខ ៧ ណ៎ាអូន ។
- តំបន់នោះ ជាតំបន់ភ្នំមែនទេបង ?



- មែនហើយអូន ..
- ហ៊ឺ ... សម្ផស្សវាចាទាំងទឹកមុខស្រពាប់ស្រពោន ខ្ញុំមិនចង់ឲ្យបងទៅធ្វើការឆ្ងាយពេកអញ្ចឹងទេ ព្រោះខ្លាចបងឈឺថ្កាត់ .., រឿងនេះបើសិនជាខ្ញុំដឹងមុន ខ្ញុំទៅសុំផល់ប្រធានមន្ទីរ ប្រហែលជាគាត់អនុគ្រោះឲ្យនៅធ្វើការជិតៗ នេះ ។

- កុំអូន ! ( បុរិន្ទពោលឃាត់ ) កុំតវ៉ានឹងការចាត់តាំងរបស់ប្រធានផ្នែកគ្រប់គ្រង ក្នុងពេលប្រជុំកាលពីម្សិលមិញ បងក៏បានឆ្លើយចំពោះមុខគេថាស្ម័គ្រចិត្តចេញទៅធ្វើការនេះដែរ អូនកុំមានការព្រួយបារម្ភណ៎ា សព្វថ្ងៃបងមានសាច់ឈាមនិង កម្លាំងកំហែងគ្រប់គ្រាន់វិញហើយអាចធ្វើពលកម្មបាន ម្យ៉ាងទៀតអ្នកទៅធ្វើការកាប់ឈើនោះ គេបានផ្តល់របបអង្ករឲ្យដាំបាយហូបគ្រាន់បើជាងនៅទីនេះ ដែលហូបតែបបរ ។

- ចាំស បងទៅនៅក្នុងព្រៃ ខំថែរក្សាសុខភាពឲ្យបានល្អណ៎ា ... នេះថ្នាំគ្រាប់មួយកញ្ចប់ត្រូវនឹងជម្ងឺគ្រុនក្តៅចុះរាគ .. សូមបងយកទៅសំរាប់ការពារខ្លួន ។

- អូន បានថ្នាំនេះពីណាមក ?
- ខ្ញុំសុំពេទ្យអង្គភាព សន្សំទុកយូរហើយ ។

សម្ផស្សប្រគល់ថ្នាំ ផ្តល់អង្រឹងរបស់នាងមួយ ក្រមាមួយ និងសាច់ក្រកណាត់មួយផ្ទាំងសំរាប់ដណ្តប់ ។ បុរិន្ទលូកដៃទទួលព្រមជាមួយនឹងក្រសែភ្នែកប្រារព្ធទៅលើទឹកមុខភរិយាកំសត់អស់ពេលដ៏យូរ ។

- បងគ្រេកអរណាស់ !.. សូមអូននៅថែរក្សាខ្លួន ការពារកិត្តិយសនិងសេចក្ដីថ្លៃថ្នូរឲ្យបានល្អផានិច្ច ។

- ចាស ខ្ញុំកំពុងធ្វើអ៊ីៗ ដើម្បីសេចក្ដីសុខរបស់បង តែដាច់ខាតខ្ញុំស្មោះត្រង់នឹងបងគ្រប់ពេលវេលា បងអញ្ជើញទៅសូមឲ្យបានជួបប្រទះតែសេចក្ដីសុខ ...

បុរិន្ទក្រឡេកទៅក្រៅ ឃើញកងកម្លាំងសន្តិសុខម្នាក់ដើរចូលមក ក៏កេះសម្ផស្សឲ្យឈប់និយាយភ្លាម ។ ភ្នាក់ងារសន្តិសុខម្នាក់នោះស្រែកបោះសម្ដីមកពីចម្ងាយ :

- ម៉េច ពូរិន្ទ រៀបចំខ្លួនហើយឬនៅ ?

- បាទ បុរិន្ទឆ្លើយបន្ទាន់ រៀបចំរួចហើយ មានអ្វីច្រើន មានតែខោអាវចាស់ៗ មួយកំប៉ុប៉ុណ្ណឹង !

- អើ បើរៀបហើយល្មមចេញទៅជួបជុំគ្នា មិត្តយើងឯណោះក៏រៀបរទេះសេះរួចហើយដែរ ។ កងកម្លាំងងាកមកឃើញនាងសម្ផស្សនៅអង្គុយមិនឆ្ងាយប៉ុន្មានពីបុរិន្ទ ក៏បន្លឺរកបែបរួសរាយ :

- អ៊ុំ មិត្តនារីសម្ផស្សទេ ?

- ចាស

- មានការអីត្រូវពិភាក្សាជាមួយពូរិន្ទឬ ?

- ចាស គ្មានការអីសំខាន់ទេ មកសំណេះសំណាលលេងនឹងគាត់បន្តិច ព្រោះគាត់ត្រូវឃ្លាតឆ្ងាយហើយ !.. មិត្តអែមទៅដែរឬ ?



- បាទ ទៅដែរ

- អញ្ចឹង សូមផ្ដាំផ្ញើជួយមើលបងប្រុសខ្ញុំផងណ៎ា ។

- បាទមិនអីទេ ! អែមឆ្លើយទាំងញញឹម ខ្ញុំបានទទួលការណែនាំពីប្រធានមន្ទីរដែរ... អញ្ចឹង បើសម្ផស្សចង់និយាយផ្ដាំផ្ញើអីនិយាយទៅ ខ្ញុំទៅចាំកន្លែងរទេះសេះមុន ។

អែមបោះជំហានចេញទៅវិញ ។ បុរិន្ទនិងសម្ផស្សនៅអង្គុយមើលមុខគ្នា យូរៗ ក៏ចេញទឹកភ្នែករលីងរលោង ។ សម្ផស្សបន្លឺវាចាឡើង :

- ណ្ហើយងងកុំឲ្យពួកគេនៅចាំយូរ បងអញ្ជើញទៅចុះ !

បុរិន្ទលើកដៃអង្អែលក្បាលនាង រួចបោះជំហានចេញទៅ ទាំងចិត្តនៅស្រណោះ ។ ឯសម្ផស្សក៏ដើរចេញមកឈរមើលដំណើរប្ដី លុះត្រារទេះសេះនាំយកទៅបាត់ ក៏វិលចូលមកក្នុងរោងបាយ ក្នុងចិត្តនាងក្រៀមក្រំពុំអាចរកពាក្យថ្លែងបាន ។

*

* *

# ១០

## ក្នុងព្រឹត្តិការណ៍ប្រែប្រួល

រន្ទះភ្លើងផ្ទះឡើងភ្លែត ៗ ! លេចចេញពីចុងព្រៃទិសខាងកើត និង មានសូរគ្រាប់កាំភ្លើងធំលាន់ព្រឹម ៗ ! ញាំប្រចពីជារៀងរាល់ថ្ងៃ ។ ព្រឹត្តិការណ៍នោះគឺសង្គ្រាមវាយលុកដ៏សាហាវព្រៃផ្សៃបំផុត របស់ ប៉ុល ពតទៅលើទឹកដីវៀតណាម ។

ចាប់តាំងពីឆ្នាំ ១៩៧៣ មក ដែលពួកអន្តរភាពវាទទីនិយមចិន បានប្រែក្រឡាស់ចិត្ត ប្រកាន់អាកប្បកិរិយាជាអមិត្តជាមួយវៀតណាម ប៉ុល ពតកូនសម្ពាយចិន ក៏ប្រែឥរិយាបថប្រឆាំងនឹងវៀតណាមដែរ ។ នៅពេលទទួលជ័យជំនះលើចក្រពត្តិអាមេរិក លន់ នល់ ប៉ុល ពតបាន ប្លន់យករដ្ឋអំណាចប្រជាជន ហើយក៏ចាប់ធ្វើសង្គ្រាមវាយវៀតណាម ដោយចំហ ។ ពួកវាបានប្រែក្លាយកងកម្លាំងប្រដាប់អាវុធប្រជាជន ទៅ ជាកម្លាំងយោធានិយមល្មោភសង្គ្រាម ។ កម្មាភិបាលគ្រប់គ្រងរដ្ឋ អំណាចទាំងមូល ក្លាយទៅជាឧបករណ៍បំរើមហិច្ឆតាលោភលន់របស់ ប៉ុល.ពត ភ្លេចអស់ធាតុវណ្ណៈមនសិការជាតិ និង មានទស្សនៈចង្អៀត ចង្អល់ជាទីបំផុត ចំពោះវណ្ណៈអធនអន្តរជាតិ ។



ម៉ាន់ប្រធានសន្តិសុខ កំពុងមានមោទនភាពចំពោះស្នាដៃនៃ អគ្គមគ្គុទ្ទេសក៍របស់ខ្លួន ។ ព្រឹកនេះ គេកំពុងអង្គុយអានសារព័ត៌មាន " ពន្លឺបូព៌ា " ( ១ ) ។ នៅលើទំព័រមួយ ដែលបានដកស្រង់សេចក្តីថ្លែង ការណ៍របស់អគ្គលេខាបក្សប៉ុល ពត មានសេចក្តីជាអាទិ៍ថា " កងទ័ព កម្ពុជា ប្រជាធិបតេយ្យបានវាយសម្រុកយ៉ាងខ្លាំងក្លានៅត្រង់តំបន់ផ្លែ សន្ទូច ចំពុះសេក . . . ឆ្លងព្រំដែនចូលទៅកំទេចបន្ទាយស្មាច់ ទទួល បានជ័យជំនះដ៏ត្រចះត្រចង់ . . . " ម៉ាន់កំពុងតែរំភើបអបអរនឹងជ័យជំនះ ដ៏ឆ្កួតលេលានេះ ។

ខណៈនោះស្រាប់តែមានគ្រាប់កាំភ្លើងត្បាល់ធ្លាក់គ្រាំង ៗ! ហាក់ ដូចជានៅជិតបង្កើយ ធ្វើឱ្យម៉ាន់ហើបគូទពីកន្លែងអង្គុយ ។ នេះមិនមែន ជាលើកទីមួយទេ ដែលធ្វើឱ្យម៉ាន់មានការភ្ញាក់ផ្អើល ប៉ុន្មានថ្ងៃមក ហើយគេបានឮស្នូរគ្រាប់កាំភ្លើងផ្ទួន ៗ ផ្គក់ចូលមកខាងក្នុងប្រទេស ។ សេចក្តីប្រកាសរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យហាក់ដូចជាផ្ទុយ នឹង សភាពការណ៍ពិត ។

ថ្ងៃនោះ មាននារសារតំបន់ ២០ ម្នាក់ជិះម៉ូតូមកផ្តល់ព័ត៌មានដល់ ម៉ាន់យ៉ាងទាន់ហន់ ។ ម៉ាន់ក្រោកឡើងក្រទឹក្រទាចាត់ការហៅកង កម្លាំងសន្តិសុខ និង អ្នកធ្វើការក្នុងមន្ទីរទាំងអស់មកប្រជុំភ្លាម ។

---

(១) ពន្លឺបូព៌ា កាលក្នុងសង្គ្រាមប្រជាជាតិជាសារព័ត៌មានរបស់ភូមិភាគបូព៌ា ក្រោយ ថ្ងៃ១៧មេសា ក្លាយទៅជាសារព័ត៌មានរបស់អង្គការមជ្ឈិមបក្សកម្ពុជាប្រជាធិបតេយ្យ។

ម៉ាន់ឡើងបើកអង្គប្រជុំនិង ចាប់មានមតិក្នុងសភាពភ័យស្លន់ស្លោ។

- សមមិត្តទាំងអស់ ! ឥឡូវនេះសភាពការណ៍នៅភូមិភាគបូព៌ាយើងមិនល្អទេ តាមពត៌មានពីតំបន់ដែលខ្ញុំទើបបានទទួលថ្មី ៗ នេះបានឱ្យដឹងថា កងទ័ពយួនបានវាយបុកទម្លាយខ្សែការពារព្រំដែន ចូលមកក្នុងទឹកដីយើងហើយ ! . . .

មតិរបស់ប្រធានសន្តិសុខ ដែលទើបបានលើកឡើងប៉ុណ្ណោះ មិនខុសអីពីការប្រកាសអាសន្ន ដែលធ្វើឱ្យសមាជិកអង្គប្រជុំទាំងមូលភ្ញាក់អាត្មា និងចាប់ភិតភ័យគ្រប់ ៗ គ្នា ។

- ស្មើសមមិត្តកុំអាលជ្រួលច្របល់ ម៉ាន់និយាយបន្តទាំងញ័រមាត់ ) ត្រូវស្តាប់សភាពការណ៍ឱ្យបាន ហើយត្រៀមខ្លួនអនុវត្តតាមបញ្ជាការរបស់ថ្នាក់លើ . . . ពត៌មានច្បាស់លាស់បានបញ្ជាក់ថា ពួកយួនលើកទ័ពមកវាយលុកចូលទឹកដីយើង មានពីរមុខព្រួញ គឺនៅខាងព្រំដែនស្វាយរៀងនិងនៅខាងពញាក្រែក ប៉ុន្តែសភាពការណ៍ដែលគួរឱ្យមានការព្រួយបារម្ភ គឺពីថ្ងៃកន្លងមកនេះ កងទ័ពយួនបានទម្លាយចូលតាមផ្លូវជាតិលេខ ៧ ឆ្លងកាត់ស្រុកពញាក្រែក ឈានមកដល់កន្លែងភូមិភាគនៅសំរោងហើយ !

អ្នកធ្វើការបន្ទាប់ពីម៉ាន់ គឺឈ្មោះសៅដែលទើបនឹងឡើងទទួលតំណែងថ្មីជាអនុប្រធានសន្តិសុខ ទទួលបន្ទុកខាងកម្លាំងប្រដាប់អាវុធ



បានឮម៉ាន់ប្រកាសប្រាប់បែបនេះ ភ្ញាក់ដូចគេឆ្លុះភ្លើងដាក់មុខ ក្រោកឡើងមានមតិស្សរដេញដោលថា :

យី សមមិត្តប្រធាន រឿងនេះខ្ញុំហាក់ដូចជាមិនជឿថាធ្លាក់ចុះដល់ស្ថានភាពទន់ខ្សោយបែបនេះសោះ ! កងទ័ពយើងនៅតាមព្រំដែនក្បាលដូចកណ្តាច់ ម៉េចក៏ឱ្យយួនចូលមកបាន ? ហើយបើចូលដល់កន្លែងភូមិភាគនៅសំរោងមែន ម្តេចក៏ខាងយើងមិនឮផ្ទុះអាវុធមួយគ្រាប់សោះ ! កម្លាំងយោធា និងកម្មាភិបាលភូមិភាគនោះទៅណា ?

ម៉ាន់មិនបានគិតទុក ក៏ឆ្លើយចេញមកទាំងប្រថុយ :

- ទឹកជាក់ទំនប់ យើងមិនអាចយកអ្វីទៅពារពាំងរាំងរាបានទេ ! កងកម្លាំងនិងកម្មាភិបាលភូមិភាគយើង បានដកខ្លួនថយតាមយុទ្ធវិធីមកប្រមូលផ្តុំគ្នានៅ តាស៊ុក មន្ទីរតំបន់ ២០ ។

- ខ្ញុំមិនយល់សោះថា ការដកខ្លួនថយតាមយុទ្ធវិធីនោះ បង្ហាញនូវការមានប្រៀបរបស់យើងទេ បើយោធាយើងខ្លាំង ម៉េចក៏មិនទៅទប់ទល់ជាមួយកងទ័ពយួន ?

- មិត្តឯង មិនជឿលើអង្គការទេឬ មិត្តសៅ ! អង្គការមិនបណ្តោយឱ្យកងទ័ពយួនមកឈរជើងលើទឹកដីនេះបានទេ ប៉ុន្តែអង្គការគ្រាន់តែដកឃ្លារកវិធីវាយបកទៅវិញប៉ុណ្ណោះ ។

ឃើញម៉ាន់ទាញក្រមាជូតញើសជាញឹកញាប់ និងបញ្ចេញសំឡេងតឹងសរសៃក សៅ ក៏បន្ទន់សម្តីមកវិញ :

បាទ ខ្ញុំជៀសមមិត្តប្រធាន ឥឡូវនេះអង្គការមានណែនាំឱ្យ
យើងធ្វើយ៉ាងម៉េច ?

– ខ្ញុំប្រាប់ហើយថា ត្រូវត្រៀមខ្លួនរង់ចាំស្តាប់ផែនការពីថ្នាក់លើ
ប៉ុន្តែបើសិនជាក្បាលទ័ពយួនរុលមកមុខទៀត យើងក៏មិនអាចសម្ងំនៅទី
នេះបាន ត្រូវដកឃ្លាចេញពីបន្ទីរទៅជ្រកនៅផ្សាយភូមិប្រជាជនមួយ
រយៈសិន ។

– អញ្ចឹងទេ ! ? ( នារីយ៉េតផ្ទាយសម្តី ) ខ្ញុំស្មានថាត្រៀមខ្លួន
ចេញទៅប្រយុទ្ធនឹងកងទ័ពយួន មិនដឹងថាមិត្តបងបបួលគ្នារត់ទេ !

ម៉ាន់ដឹងខ្លួនថានិយាយត្រឡប់ត្រឡិនដូចគោផាន់កន្ទះឯង ត្រូវនារី
យ៉េតប្រើសម្តីផ្តាញ់ផ្តាលឱ្យ ក៏កប់យោបល់ត្រឹមនោះ ។ នារីយ៉េតមាន
មតិបំភ្លឺតទៅទៀត :

– តាមខ្ញុំគិត ពីកន្លែងភូមិភាគនៅសំរោង_ដូនតី មកមន្ទីរសន្តិសុខ
ស្រុកនេះ មានចម្ងាយដល់ទៅជិតសែសិបគីឡូម៉ែត្រ ម៉េចក៏ប្រញាប់ភិត
ភ័យនាំគ្នារេចសម្ងាយរត់ !

– អើ បើមិត្តឯងមិនខ្លាចងាប់ទេ សម្ងំនៅទីនេះទៅ ខ្ញុំលើកឡើង
គ្រាន់តែបង្ហាអសន្តិសុខមកដល់ទេតើ !

ស្នូរគ្រាប់កាំភ្លើងធំធ្លាក់គ្រាំង ៗ ញ័រកក្រើកដីហាក់ដូចជាខិត
កាន់តែជិតមកៗ និងមានលេចឮស្នូរគ្រាប់កាំភ្លើងយន្តបាញ់ចេញជាខ្សែ



យ៉ាងច្បាស់ក្រឡែត ។ សមាជិកអង្គប្រជុំក៏បែកគ្នាខ្ចាត់ ដូចត្រីចង្វាត្រូវ
គគោះទឹកបង្អើល ។

ម៉ាន់និងសៅនៅឈរមិនមាំងកាំងស្មារតីនឹងតុអធិបតីនោះ ។
ពេលនោះគេក្រឡេកទៅក្រៅ ឃើញម៉ូតូហុងដាជិះដោយយុវជនម្នាក់
បោលតាមភ្លឺស្រែមកចំខ្លួន ។ ជននោះជានារសាររបស់ស្រុក បាន
នាំបញ្ជាពីអង្គការគេមកប្រគល់ឱ្យម៉ាន់ :

សមមិត្តប្រធានសន្តិសុខ តាមពត៌មានពីតំបន់ ២០ ដែលមន្ទីរ
ស្រុកទើបបានទទួលថ្មីៗនេះថែមទៀតបានឱ្យដឹងថា កងទ័ពយួនដែល
បានចូលមកដល់កន្លែងភូមិភាគ មានមុខព្រួញសំដៅមកស្រុកកំចាយមារ
និងមេសាងយើងហើយ គោលបំណងទៅចាប់ពួកគេដែលចូលតាម
ច្រកស្វាយរៀងឥឡូវនេះ តាមបញ្ជាពីសមមិត្តលេខាស្រុក ស្នើសមមិត្ត
ប្រធានឡើងទៅទទួលផែនការឱ្យបានច្បាស់ពីតំបន់ !

– អ្ហះ ម៉ាន់ឧទានទាំងភ្នែកក្រឡាប់ចក្រ រឿងនេះវឹវរធំហើយ !
អង្គការឱ្យទៅឥឡូវនេះ ឬ ?

– ទៅផាបន្ទាន់ !

– មិត្តសៅ ! ម៉ាន់ងាកនិយាយកសៅ ទុកមិត្តយ៉េតឱ្យទទួល
ខុសត្រូវទីនេះបានហើយ មិត្តទៅភ្ជាប់សភាពការណ៍និងទទួលផែន
ការជាមួយខ្ញុំ ។

* * *

វត្តមាននៃកងទ័ពវៀតណាម នាចុងខែធ្នូ ឆ្នាំ ១៩៧៧នោះ មិនអាចចាត់ទុកថា ជាការរំលោភមកលើអធិបតេយ្យភាពកម្ពុជាទេ ប៉ុន្តែគ្រាន់តែជាការព្រមានមួយចំពោះអ្នកកាន់អំណាចកម្ពុជាប្រជាធិបតេយ្យ ដែលបានបង្កឡើងនូវសង្គ្រាមឈ្លានពានយ៉ាងងងើលទៅលើទឹកដីរបស់គេ ។ ប្រការដែលគួរឱ្យកត់សំគាល់ កងទ័ពវៀតណាមចូលមកនោះ មិនបានធ្វើឱ្យមានគ្រោះមហន្តរាយដល់អាយុជីវិតនិងទ្រព្យសម្បត្តិរបស់ប្រជាជនឡើយ ។ ក្រោយពីបង្ហាញសមត្ថភាពខាងយោធាមួយរយៈខ្លីប៉ុណ្ណោះ កងទ័ពនេះក៏បានដកខ្លួនថយទៅវិញដោយសុវត្ថិភាព ។

ក៏ប៉ុន្តែ ពេលនោះ បែរជាមានសេចក្តីប្រកាសរបស់គណៈ ៨៧០ ១) ចេញផ្សាយក្តែងៗថា " កងទ័ពទាំងបីប្រភេទ ឈ្លប តំបន់ និងកងពលស្រួចរបស់កម្ពុជាប្រជាធិបតេយ្យ បានវាយរុញច្រានកងទ័ពវៀតណាមឈ្លានពានឱ្យដកថយទៅវិញ សំរេចបានស្នាដៃនិងជ័យជំនះដ៏ធំធេង " ។ ឯកសារសារាចរនេះ ត្រូវបានគេផ្សព្វផ្សាយ និងរៀនសូត្រដល់កម្មាភិបាលទូទាំងប្រទេស ។ ប៉ុន្តែអ្នកណាក៏ដឹងដែរថា វាគ្រាន់តែជាប្រការបិទបាំងការអាម៉ាស់មុខ និង ការបរាជ័យនៃអ្នកកាន់អំណាចកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ។

ជាក់ស្តែងអ្នកធ្វើការនៅតាមមន្ទីរអង្គភាពនានា បានរត់ចោលកន្លែងទៅជ្រកប្រមកនៅតាមផ្ទះប្រជាជន ទោះបីជាកងទ័ពវៀតណាមបាន

---

( ១ ) មជ្ឈិមបក្ស ប៉ុល ពត



ដកថយទៅវិញបាត់ស្រមោលហើយក្តីក៏មិនទាន់ហ៊ានចូលទៅធ្វើការ ។

ក្នុងពេលដែលគេកំពុងប្រមូលគ្នារៀបចំឡើងវិញនោះ ស្រាប់តែលេចយុវជនឈ្មោះអែម ទៅដល់ទីនោះដែរ ។ អែមដែលត្រូវគេចាត់តាំងឱ្យទៅកាប់ឈើនៅក្នុងព្រៃស្រុកទឹកជ្រៅ បានគេចខ្លួនចៀសពីកងទ័ពវៀតណាម ហើយទើបនឹងរត់មកដល់ កន្លែងដើមវិញ ។

នាងសម្ផស្សក្រឡេកឃើញយុវជនអែម នឹកចាប់អារម្មណ៍ភ្លាមទៅដល់បុរិន្ទ ក៏គាត់ទៅសួរដំណឹងជាបន្ទាន់ :

មិត្តអែម មកដល់ពីអង្កាល់ ?

– បាទ ! អ៊ំ សម្ផស្ស ! ខ្ញុំធ្វើដំណើរអស់រយៈមួយអាទិត្យហើយ ទើបនឹងមកដល់នេះ !

– ពួកយើង មកទាំងអស់គ្នា ឬ ?

– ហ៊ឺ . . សម្ផស្សអើយ ! ( អែមនិយាយក្នុងទឹកមុខស្រូបស្រូត ) និយាយលាក់បាំងអី ខ្ញុំមកនេះរត់រួចខ្លួនម្នាក់ឯងទេ រីឯមិត្តយើងផ្សេងទៀត និងអ្នកទោសទាំងអស់ ត្រូវកងទ័ពយួនព ចាប់ខ្លួនបានអស់ហើយ !

– អ្ហក ! ចុះបងបុរិន្ទ យ៉ាងម៉េចដែរ ?

– បុរិន្ទ ក៏ត្រូវបានដៃគេដែរ !

– អ៊ុះ ! បងបុរិន្ទត្រូវគេចាប់ខ្លួន ! . .

– ពិតហើយ ! ក្នុងសភាពការណ៍មួយសប្តាហ៍កន្លងមកនេះ កងទ័ពយួនបានចូលមកពេញស្រុកពញាក្រែក–ទឹកជ្រៅ ហើយបានរុកចូល

នៅចំកន្លែងពួកយើងធ្វើការនៅក្នុងព្រៃនោះតែម្តង ! អ្នកទាំងអស់ស្ថិតនៅក្នុងការឡោមព័ទ្ធគ្មានច្រកចេញ មានតែខ្ញុំម្នាក់ទេដែលប្រឹងយរត់កាត់ព្រៃ និង គ្រាប់រំសេវរហូតបានរួចខ្លួនមកដល់ទីនេះ ។

សម្លស្សទន់ដៃទន់ជើងស្រុតខ្លួនចុះ ចាប់យំសសិត ។ នាងខំចម្ងីរចាស្សួរបញ្ជាក់អែមថែមទៀត :

មិត្តអែម ជួយគិតខ្ញុំផងមើល បើបងបុរិន្ទត្រូវគេចាប់ខ្លួនបានអញ្ចឹង តើគេយកទៅធ្វើទុក្ខទោសយ៉ាងណាឬក៏សម្លាប់ ?

— ហ៊ឺ . . . កងទ័ពយួន និង កងទ័ពកម្ពុជាប្រជាធិបតេយ្យយើងជាសត្រូវបដិបក្ខនឹងគ្នា តាមខ្ញុំស្មាន មើលទៅចៀសមិនរួចពីត្រូវគេសម្លាប់ទេ !

— តែបងបុរិន្ទ ជាអ្នកទោស មិនមែនយោធាឯណា ?

— ទោះជាអ្វីក៏ដោយ ក៏ត្រូវស្លាប់ដែរ មិត្តសម្លស្សឯងមិនចាំប្រវត្តិសាស្ត្រទេឬ បួនយកក្បាលខ្មែរ ដាំតែអុង !

សម្លស្សងឹតមុខស្ងួន្យ យំរៀបរាប់ :

— ឱ បងបុរិន្ទ ! អំណើះពីពេលនេះទៅ អូនលែងបានយល់មុខបងហើយ ! . . .

ខណៈនោះគេឃើញនារីយ៉េតដើរបង់ប៉ោយដៃញាប់ស្មេ មកដល់ក៏ស្រវែងសម្តីថា :



— យីនែ៎ ! មិត្តយុវ័ន.នារីពីរនាក់នេះនៅអង្គុយជជុំគ្នាអី ម៉េចមិនដឹងថាអង្គការហៅទៅប្រជុំរៀនសូត្រទេឬ ?

— ទៅប្រជុំ ឥឡូវនេះឬបង ? ( អែមសួរ )

— អើ ! ( នារីយ៉េតដាក់ភ្នែកស្គាល់នាងសម្លស្សក៏ឧទានថែម ) ម៉ោក ! នេះនារីសម្លស្សទេ នារីឯងកើតស្អីបានជាយំពព្រិចអញ្ចឹង ?

— បងប្រុសរបស់នាងឈ្មោះ រិន្ទ ត្រូវយួនចាប់ . . . ( អែមឆ្លើយជំនួស )

— អ៊ូ បើបានដៃគេហើយ ប្រាកដជាត្រូវគេវះពោះច្រកស្មៅ . . . ងាប់បាត់ទៅហើយ ! នារីឯងនៅស្តាយស្រណោះអី ទៅ ! ទៅរៀនសូត្រ !

សម្លស្សឈឺចាប់នឹងសម្តីទ្រគោះបោះបោកនេះណាស់ តែនាងរកពាក្យពោលតតតមិនរួចក៏ខំមាត់សង្កត់ចិត្ត ក្រោកឡើងបោះជំហានដើរទៅទាំងអាការៈធីងធោង ។

* * *

រំលងមកជាងបួនខែ អង្គភាពនានានៅស្រុក តំបន់និងភូមិភាគត្រូវបានរៀបរយឲ្យមានសណ្តាប់ធ្នាប់ឡើងវិញ ហើយអង្គការគេក៏ខិតខំពង្រឹងការងារជាបន្តបន្ទាប់ ។ ប៉ុន្តែ សកម្មភាពគ្រប់ផ្នែកមិនមានការវិវឌ្ឍរីកចំរើនទៅមុខទេ ព្រោះស្មារតីអ្នកធ្វើការហាក់ដូចជាបាក់ស្រុតធ្លាក់ចុះខុសប្លែកធម្មតា ។ ព្រឹត្តិការណ៍សង្គ្រាមនៅតាមព្រំដែនក៏ចុះ

ខ្សោយ ។ ផ្ទុកនេះតែមានការរំពើតរំពើង បន្តិចឮថាអ្នកនេះក្បត់ អ្នកនោះក្បត់ ចាប់សម្លាប់គ្នាជាបន្តបន្ទាប់ ។

ម៉ានប្រធានសន្តិសុខ ចាប់ប្រើអំណាចអាជ្ញាយ៉ាងខ្លាំងក្លា ។ ទន្ទឹមនឹងការងារ ម៉ាន់ក៏នៅមានគំនិតអត្តទត្តបុគ្គល ។ គេនៅតែចចេះស្នើគណៈតំបន់យកនាងសម្ផស្សធ្វើជាភរិយា ប៉ុន្តែអង្គការគេសំរេចដាច់ខាតមិនឲ្យម៉ាន់រៀបការជាមួយនារីនេះឡើយ ។ ម៉ាន់អស់សង្ឃឹម ទីបំផុតក៏កើតមានគំនិតមួយខ្មៅក្រខ្វក់ ។

រសៀលថ្ងៃមួយ ម៉ាន់អង្គុយសញ្ជប់សញ្ជឹងនៅក្នុងបន្ទប់ ជួនជាក្រឡេកទៅឃើញនាងសម្ផស្សដើរទៅធ្វើការ គេក៏ហៅឲ្យចូលទៅជួបនឹងគេមួយរំពេច ។

- សម្ផស្ស !
- ចាស៎ពូ . . .
- មិត្តឥឡូវនេះ ម៉េចក៏ចុះស្គមខ្លាំងម្ល៉េះ ?
- ចាស៎ លំបាកចិត្តពេក . . . ( សម្ផស្សឆ្លើយតាមត្រង់
- អូ៎ . . . រឿងបាត់ខ្លួនបងប្រុសឈ្មោះវិននោះ ឬ ?
- ចាស៎ !
- ហ៊ឺ . . . ខ្ញុំក៏អាណិតមិត្តនារីផងណា៎ មិត្តអង្គុយសិនមក ខ្ញុំនិយាយបន្តិច . . .



- ខ្ញុំប្រញាប់ទៅធ្វើការណា៎ពូ ( សម្ផស្សបន្លឺប្រុងបោះជំហានចេញ )
- អើកុំអាល ( ម៉ាន់ឃាត់ ) ខ្ញុំមិនស្រួលខ្លួនទេ សុំមិត្តកោសខ្យល់ឲ្យខ្ញុំសិន ។
- ខ្ញុំមិនចេះកោសទេពូ

កុំធុញទ្រាន់អីសម្ផស្ស ! បើមិនចេះរៀនកោសទៅណា៎ះ ! ខ្ញុំមានជម្ងឺ បានជាខ្ញុំត្រូវការប្រើមិត្ត ទំ៎ះ សេនកោសខ្យល់ និង ចានប្រេងទៅលើតុ !

ចំពោះមុខអ្នកមានអំណាច និងជាថ្នាក់ដឹកនាំរបស់ខ្លួន សម្ផស្សនឹងប្រកែកតទៅទៀតមិនកើត សុខចិត្តទទួលធ្វើកិច្ចការនោះ ។ គ្រាន់តែសម្ផស្សចូលទៅអង្គុយជិត ម៉ាន់ស្រវាចាប់កដៃនាងជាប់ ហើយបញ្ចេញទឹកមុខញញឹមគួរឲ្យខ្លាច ។ សម្ផស្សនឹកគិតភ្លាមថា តាំងពីដើមមកម៉ាន់ជាប្រធានសន្តិសុខបានប្រព្រឹត្តនូវអំពើឃោរឃៅរាប់មិនអស់លើជនដទៃ តែគេមិនដែលធ្វើអ្វីអាក្រក់មកលើរូបនាងទេ ឥឡូវនេះម៉ាន់ប្រែអាកប្បកិរិយាប្លែកណាស់ !

- ពូ ! . . ពូធ្វើម៉េចអញ្ចឹង ?

សម្ផស្សបន្លឺព្រមទាំងកន្ត្រាក់ដៃចេញដោយភិតភ័យ តែបុរសខ្លាំងកញ្ចាស់ប្រើក្រញាំក្តាប់ណែន :